
ទស្សនាវដ្តី
លេខ ៨
ពុទ្ធិកវិទ្យាល័យ
ទីចាត់ការ វត្តចេង្កា សង្កាត់លេខ ៦
ភ្នំពេញ

Don Offert par M. Imprimerie Viriya ppenh

# មាតិការឿង


| | | |
|---|---|---|
| ភិក្ខុ អាំ-សួន (ហៅហម) | ពុទ្ធជយន្តិ | ទំព័រទី ១ |
| បណ្ឌិត សម-សុខុម | ពុទ្ធទស្សនៈ (ទឹងតបប់) | ,, ៦ |
| | ដំណឹងសាសនា | ,, ៩ |
| មហា ប៉ាង-ទិត | ស្ថានការណ៍នៅសហភាពភូមា | ,, ១៤ |
| | សេចក្ដីរាយការណ៍អំពីការប្រជុំនៃគណៈកម្មាធិការទីប្រឹក្សាពុទ្ធគយា | ,, ១៨ |
| | របនាវិលាសវាក្យភាសាអង់គ្លេស(ត) | ,, ២២ |
| | ពាក្យថ្មីរបស់គណកម្មការវប្បធម៌ | ,, ២៤ |
| | បូរាណនិវេសន៍ | ,, ២៨ |
| ព្រះគ្រូបុរត្ថិមវាលី អ៊ុំ-បេវ | ធនញ្ជយបណ្ឌិត | ,, ៣១ |
| | ក្រុងរ៉ង្គូន ប្រទេសភូមា | ,, ៣៧ |
| | ជ័យប្រាជ្ញ (ត) | ,, ៣៩ |


## ថ្លៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលជាវ

សូមផ្ញើបំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

# សេចក្ដីជូនដំណឹង

សូមព្រះថេរានុត្ថេរៈនិងអស់លោក-អ្នក-មិត្តទាំងឡាយ ដែលបានជាវទស្សនាវដ្ដីនេះ ហើយពុំទាន់បានបង់តម្លៃជាវនៅឡើយនោះ សូមទានមេត្តាផ្ញើបច្ច័យប្រាក់ទៅបង់តម្លៃឲ្យទានដោយអនុគ្គហភាព ។ ព្រោះពលភាពនៃឱកាសសម្រាប់បំណាយបោះពុម្ពនោះ កាន់តែខ្សត់ខ្សោយណាស់ទៅហើយ ។

សូមព្រះថេរានុត្ថេរៈនិងអស់លោក-អ្នក-មិត្តទាំងឡាយ មេត្តាជួយឧបត្ថម្ភទំនុកបំរុងជីវភាពនៃទស្សនាវដ្ដីនេះឲ្យមានពលភាព-វឌ្ឍនភាពជាស្ថាពរតទៅឲ្យទានផង ! ។

សូមអរគុណទុកជាមុនដ៏ជ្រាលជ្រៅដោយសេចក្ដីស្មោះស្ម័គ្រ ! ។

# ពុទ្ធជយន្តិ

បុណ្យឆ្លងអាយុខួបជាគំរប់ ២៥០០ ព្រះវស្សានៃព្រះសម្មាសម្ពុទ្ធ

ប្រទេសឥណ្ឌា, លង្កា, ភូមាជាដើម គេបានសន្មត់ថា អាយុកាលនៃព្រះពុទ្ធសាសនា គ្រប់ ២៥០០ ព្រះវស្សា នៅថ្ងៃទី ២៥ ខែឧសភា គ.ស. ១៩៥៦ នេះ ។ ព្រោះហេតុនេះរដ្ឋាភិបាលឥណ្ឌា បានអនុមតិឲ្យចាត់ចែងធ្វើបុណ្យពុទ្ធជយន្តិ គ្រប់កន្លែងបូជនីយស្ថាន ទីកន្លែងដែលមានអនុស្សាវរីយ៍ព្រះពុទ្ធសាសនា ព្រមទាំងចំណាយប្រាក់ថវិកាជាច្រើនរយលានរូពី ដើម្បីជួសជុលបុរាណស្ថាននោះៗដែលបាក់បែកទ្រុឌទ្រោម, លើកថ្នល់តម្រង់ពីកន្លែងមួយទៅមួយ ត្រង់ទីណាដែលពុំទាន់មានថ្នល់ល្អ, ពង្រាបដី, ស្ថាបនាសណ្ឋាគារជាដើម ។

កន្លែងដែលសំខាន់ជាងគេគឺពោធិគយា (ពុទ្ធគយា) ជាកន្លែងដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ។ ទិដ្ឋភាពនៃពោធិគយាបានប្រែប្រួលជាងពីដើមច្រើន, វត្តបាក់បែកខ្ទាតខ្ចាយរាត់រាយក្នុងទីនោះ ៗ គេបានប្រមូលផ្តុំជារបៀបរៀបរយ, មានកំពែងនឹងផ្លូវថ្នល់ក្រាលឥដ្ឋព័ទ្ធជុំវិញ ប្រដាប់លំអរដោយអំពូលភ្លើងអគ្គិសនីព្រោងព្រាត ។ កន្លែងដែលធ្លាប់គ្រហេងគ្រហូងរង្ជុកពីដើម ឥឡូវត្រឡប់ទៅជារាបស្មើមានដាំស្មៅនឹងគុម្ពផ្កាដេរដាស ។ ដើមពោធិព្រឹក្សបញ្ចេញស្លឹកត្រួយខៀវខ្ចីស្រស់បំព្រងសំដែងអាការៈហាក់ដូចជាត្រេកអរីករាយបំរុងទទួលសក្ការបូជាអំពីពុទ្ធជនសាកលលោក ។ ក្នុងពេលរាត្រី ព្រះស្តូបនៃពោធិគយាដែលមានគោមបញ្ចាំងគ្រប់ជ្រុងភ្លឺចិញ្ចែងចិញ្ចាចឃើញហាក់ដូចជាវិមានអណ្តែតឰដ៏អាកាស ។

ប្រជាជនទាំងជាតិឥណ្ឌាទាំងបរទេស ដោយស្មានប្រហែល២សែននាក់ បានមករួមធ្វើពិធីបុណ្យនៅពោធិគយា ។ ពិធីបុណ្យចាប់ផ្តើមពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៥ ខែ

ឧសភា ។

ថ្ងៃទី ២៣ ឧសភា គ.ស. ១៩៥៦

វេលាម៉ោង៦ព្រឹកព្រះសង្ឃប្រមាណ ៥០ អង្គចូលប្រជុំសូត្រធម៌នមស្ការក្នុងព្រះស្តូបនឹងក្រោមដើមពោធិព្រឹក្ស, បន្ទាប់មកពួកគ្រហស្ថចូលនមស្ការ ធ្វើសក្ការបូជាផ្កាភ្ញីជាដើម ។ ម៉ោង១០ព្រឹកមានពិធីរៀបក្បួនដង្ហែរថ្វាយព្រះចេញពីគ្រឹះស្ថាននៃមហាពោធិសមាគម ប្រទក្សិណព្រះស្តូបនឹងពោធិព្រឹក្ស ៣ ជុំ ហើយយកថ្វាយទាំងតុ ទាំងថាស ដាក់តម្រៀបពោរពាសលើរតនបល្ល័ង្ក សូត្រវេរថ្វាយព្រះហាក់ដូចជាព្រះអង្គគង់ធរមាននៅឡើយ ។ បន្ទាប់ពីនោះពួកពុទ្ធបរិស័ទរៀបចង្ហាន់ថ្ងៃត្រង់ប្រគេនព្រះសង្ឃគ្រប់អង្គ ។

ម៉ោង ៦ ល្ងាច មានកាលប្រជុំពួកគណកម្មការចាត់ចែងការមហាវិហារពុទ្ធគយា ដែលមានលោកពមនន្ទប្រសាទសិង្ហ លេខាធិការនៃគណកម្មការនោះថ្លែងបើកប្រជុំនឹងអញ្ជើញសមាជិក ទាំងបព្វជិតទាំងគ្រហស្ថ ៗ តមក ឯ.ឧ. កទ្រនាថវរមា រដ្ឋមន្ត្រីក្រសួងសិក្សាធិការរដ្ឋពិហារ ឡើងថ្លែងអំពីលទ្ធិពុទ្ធសាសនា យ៉ាងពិស្តារហើយគេក្រោះក្បាយ ដែលស្នូរទះដៃបានលាន់ឮឡើងយ៉ាងយូរក្នុងពេលបញ្ចប់ ។ ឯ.ឧ.វរមា បានអធិប្បាយថា សព្វថ្ងៃសកលលោកកំពុងឈរមុខខំប្រឹងស្វែងរកសន្តិសុខ ដោយបានបង្កើតអង្គការនេះអង្គការនោះជាច្រើនបែបច្រើនយ៉ាង ៗ ឯអង្គការទាំងនោះគេអាចបែងចែកដោយការប្រតិបត្តិទៅជាពីរផ្នែក ពួកទី ១ ចង់ស្ថាបនាសន្តិសុខដោយប្រើអាវុធបង្កើតបំបាំងដែលសព្វថ្ងៃកំពុងអួតអាងកម្លាំងគ្រាប់បែកបរមាណូជាដើម , ពួកទី ២ ចង់ស្ថាបនាសន្តិសុខដោយឧបាយចរចារតាមផ្លូវស្ងប់ស្ងាត់បញ្ឈប់សង្គ្រាម រឹតចំណងមិត្តភាពរវាងប្រទេស

មួយនឹងមួយ គឺលើកយកព្រះពុទ្ធសាសនាមកជាផ្លូវប្រតិបត្តិ ,, ។ ឯ.ឧ. បានពន្យល់បន្ថែមទៀតថា បញ្ចសីលគឺតំណាងនៃមិត្តភាព ៥ ១ ដែលបណ្ឌិតនេរូបានផ្ដើមធ្វើជាមួយប្រទេសចិនកុម្មុយនិស្ត ភូមា កម្ពុជាជាដើម ដែលជាខប្រតិបត្តិសំខាន់បំផុតអាចឲ្យយើងសង្ឃឹមថានឹងពុំមានការបៀតបៀនរំលោភគ្នាទៅវិញទៅមកនោះ ក៏សុទ្ធតែបានជ្រើសយកតាមទ្រឹស្ដីនៃពុទ្ធសាសនា ។ ដូច្នេះបើយើងចង់បានសន្ដិសុខមែន ៗ នោះមានតែឧបាយមួយទេគឺនាំប្រតិបត្តិតាមផ្លូវព្រះពុទ្ធសាសនា ,, ។

លុះ ឯ.ឧ. វរមា ថ្លែងចប់ហើយ ទើបព្រះមហាថេរ ជ. កស្សប ចាងហ្វាងកិត្តិយសនៃវិជ្ជាស្ថាននាលន្ទាឡើងថ្លែងអំពីជីវប្រវត្តិនៃព្រះសម្មាសម្ពុទ្ធ យ៉ាងសង្ខេប ដែលរួមសេចក្ដីថា ថ្ងៃពេញបូណ៌មីនៃវិសាខជាថ្ងៃត្រៃមង្គលនៃព្រះពុទ្ធសាសនា គឺព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រសូត្រត្រាស់ដឹងនិងបរិនិព្វាននៅថ្ងៃនេះ ។ ព្រះមហាថេរបានអធិប្បាយយ៉ាងវែងតទៅទៀត អំពីអដ្ឋង្គិមគ្គ និងមហាករុណាធិគុណនៃព្រះសម្ពុទ្ធ ។

បន្ទាប់ពីនោះមានពួកបរិញ្ញាបណ្ឌិតចំនួន ១០ នាក់ឡើងថ្លែងម្នាក់ម្ដង ៗ អំពីមតិរបស់ខ្លួនចំពោះលទ្ធិព្រះពុទ្ធសាសនា មានរៀងជាពាក្យកាព្យសរសើរគុណបារមីនៃព្រះ-ពុទ្ធជាម្ចាស់នៅខាងដើមឬចុងចប់នៃបាឋកថារបស់ខ្លួនៗ ទៀតផង ។ បាឋកថារបស់គេទាំងនោះសឹងជាទីចាប់ចិត្តនៃអ្នកស្ដាប់ក្រៃពេក , ស្ទើរលាន់មាត់សរសើរនិងទះដៃស្ទើរតែរាល់ប្រយោគ ។ ពេលប្រជុំចប់នៅម៉ោង ៩ , ៣០ យប់ ។

ថ្ងៃទី ២៤ ឧសភា គ.ស. ១៩៥៦

ថ្ងៃនេះជាថ្ងៃប្រជុំធំ មានប្រជាជនកកកុញលើសលុនជាងថ្ងៃមុន ។

ម៉ោង ៦ ព្រឹក បរិស័ទទាំងបព្វជិតទាំងគ្រហស្ថ ជួបជុំហែរប្រទក្សិណព្រះស្តូបនឹងពោធិព្រឹក្ស ៣ ជុំ ហើយព្រះសង្ឃទាំងអស់ ពីប្រទេសផ្សេង ៗ បូលគង់ក្រោមម្លប់ពោធិព្រឹក្ស សូត្រធម៌នមស្ការ, បរិត្ត, ផ្សាយមេត្តាជាដើម មួយក្រុមម្តង ៗ តាមដែលមកពីប្រទេសផ្សេង ៗ គ្នា ។ ពេលសូត្រធម៌នោះគេបានបន្តខ្សែផ្សាយសម្លេងតាមរលកធាតុអាកាសឥណ្ឌៀផង ។ ព្រះសង្ឃពីនានាប្រទេសដែលបានសូត្រធម៌ផ្សាយក្នុងពេលនោះគឺព្រះសង្ឃឥណ្ឌៀ, លង្កា, ភូមា, ខ្មែរ, សៀម, យួន ។ ព្រះសង្ឃខ្មែរដែលបានទៅរួមប្រជុំនៅពោធិគយានោះ គឺសមណៈនិស្សិតខ្មែរ ៣ រូបដែលសមាគមមិត្តពុទ្ធិក-វិទ្យាល័យបានបញ្ជូនទៅឲ្យសិក្សានៅវិជ្ជាស្ថាននាលន្ទា (ឥណ្ឌៀនោះ) ។

ដល់ម៉ោង ១០ មានពិធីវេរថ្វាយដង្វាយព្រះ ហើយប្រគេនចង្ហាន់សង្ឃដូចថ្ងៃមុន ។

ម៉ោង ៦ ល្ងាច គណកម្មការបុណ្យ នឹងព្រះសង្ឃ ព្រមទាំងគ្រហស្ថជួបជុំត្រៀបត្រានៅក្នុងបរិវេណ ជុំវិញព្រះស្តូបនឹងពោធិព្រឹក្ស ចាំទទួល ឯ.ឧ. រដ្ឋមន្ត្រីឧត្តមស្នងការរដ្ឋពិហារ ។ ម៉ោង ៦,៣០ ឯ.ឧ. អញ្ជើញមកដល់ព្រមទាំងសមាជិកជាច្រើនរូប លុះ ឯ.ឧ. បួលថ្វាយបង្គំនមស្ការ បូជាព្រះពុទ្ធរូបក្នុងព្រះស្តូបនឹងរតនបល្ល័ង្ក ក្រោមដើមពោធិព្រឹក្សរួច ក្បួនហែកចាប់ហែប្រទក្សិណ ព្រះស្តូបនឹកពោធិ-ព្រឹក្ស ហើយហែរចេញបណ្តោយតាមថ្នល់ទៅកាន់មណ្ឌបជាទីប្រជុំ ដែលតាំងនៅប្រមាណ ៣០០ ម៉ែត្រ ខាងលិចពោធិព្រឹក្ស ។

ម៉ោង ៧,៣០ យប់, លុះលោកប្រធានគណៈកម្មការបុណ្យបានឡើងថ្លែងបើកប្រជុំហើយ, ឯ.ឧ. រដ្ឋមន្ត្រីឧត្តមស្នងការ ក៏ចាប់ថ្លែងរៀបរាប់អំពីលទ្ធិពុទ្ធសាសនានឹងសាសនាព្រាហ្មណ៍យ៉ាងពិស្តារ ។ តពីនោះព្រះមហាថេរ កស្សប បានហ្វាងកិត្តិយស

វិជ្ជាស្ថាននាលន្ទា បានយកសំណៅព្រះត្រៃបិដកជាភាសាហិណ្ឌី ដែលលោកបានប្រែរៀបរៀងជាមួយគណៈកម្មការលោកនៅនាលន្ទា ប្រគល់ជូនដល់ ឯ.ឧ. ដែលជាតំណាងរដ្ឋាភិបាល សូមឲ្យជួយឧបត្ថម្ភកងការបោះពុម្ពផ្សាយ ហើយថ្លែងសុន្ទរកថាយ៉ាងវែងអំពីតម្លៃនៃព្រះពុទ្ធសាសនាដល់ប្រជុំជនថែមទៀត ។ ឯ.ឧ. រដ្ឋមន្ត្រីឧត្តមស្នងការ បានថ្លែងអំណរសរសើរ ស្នាដៃនឹងសេចក្ដីព្យាយាមរបស់លោកគ្រូកស្សប ហើយយល់ព្រមទទួល ជួយឧបត្ថម្ភ កងការបោះពុម្ពផ្សាយព្រះត្រៃបិដក ។

បន្ទាប់ពីនោះ កវីចំនួន ១៥ នាក់ មានបណ្ឌិតគោវិន្ទពល្លភប័ន្ត រដ្ឋមន្ត្រីក្រសួងមហាផ្ទៃសហភាពឥណ្ឌាជាដើម បានឡើងថ្លែងម្ដងម្នាក់ៗ រហូតដល់ម៉ោង ១០ យប់ ទើបចប់ប្រជុំ ហើយមានបញ្ចាំងភាពយន្ត អំពីព្រះពុទ្ធសាសនាដល់ម៉ោង ១២យប់ ទើបឈប់ ។

ថ្ងៃទី ២៥ ឧសភាពុំមានការអ្វីប្លែក ជាងថ្ងៃមុនច្រើនទេ គឺមានការហែរដង្វាយព្រះជាដើម កងពេលព្រឹកដូចគ្នា ។ ពេលម៉ោង ៦,៣០ ល្ងាច មានការប្រជុំយ៉ាងធំ ចំនួនតែជាង១ម៉ោង ដែលមាន ឯ.ឧ. រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ អញ្ជើញមកជាកិត្តិយសកងពេលប្រជុំផង ។

បន្ទាប់ពីពេលប្រជុំ មានលេងល្ខោនរាំអំពីវប្បធម៌បុរាណនៃប្រទេសឥណ្ឌា រហូតដល់ម៉ោង ១១ យប់ ។ ចប់ ។

ភិក្ខុ វីរបណ្ឌិតោ ( អាំ - សួន ហៅហម )

វិជ្ជាស្ថាននាលន្ទា ថ្ងៃទី ៣១ ឧសភា ឆ្នាំ ១៩៥៦



## ពុទ្ធទស្សនៈ (គ)

បំណែកបុគ្គលដែលមិនបានបំពេញដោយពេញទី នោះគួរស្វែងរកការបេះដឹងក្នុងផ្លូវព្រះពុទ្ធសាសនា ឲ្យក្រៃលែងឡើង, កាលបើបានសក្ការបូលចិត្តហើយ សូម្បីមានសទ្ធាក៏មិនគួរវិតក្កក្នុងការដែលមិនអាចនឹងប្រតិបត្តិបាននោះឡើយ ព្រោះថាអ្នកដោយ មិនសំខាន់ស្មើនឹងចិត្តយើងទេ បើចិត្តយើងនឹកថាៈ នឹងប្រតិបត្តិហើយក៏គង់នឹងធ្វើបាន សូម្បីធ្វើបានបន្តិចបន្តួចក៏នៅប្រសើរជាងដែលមិនបានធ្វើសោះ ៗ តែបើចិត្តរញ្ញញថាៈ នឹងធ្វើនឹងប្រតិបត្តិមិនបាន ក៏គង់មិនបានធ្វើដោយពិត ៗ បើប្រាថ្នាជាមនុស្សល្អពិត ៗ ដែលសមហៅថាជាពុទ្ធសាសនិក ត្រូវហ្វឹកហ្វឺនបង្គាប់ចិត្តរបស់ខ្លួនឲ្យលុះនៅក្នុងអំណាចរបស់ខ្លួន ទាល់តែអាចបង្គាប់ឲ្យនឹកធ្វើអ្វីបានតាមប្រាថ្នា ៗ សូម្បីចិត្តគិតនឹកកាថយ

ក៏គួរគប់រុំចិត្តឲ្យលះសេចក្ដីកំថយនោះឲ្យទាល់តែបាន ។

នៅមានជនមួយពួកទៀត មានការងឿងឆ្ងល់ ព្រោះសេចក្ដីចូលចិត្តថា: «ខ្លួនជាមនុស្សខ្វាត ហើយបានពោលថា នឹងបំពេញឲ្យកន្លងវេលាទៅធ្វើអ្វី? ព្រោះថាបើបំពេញយ៉ាងណា ៗ ក៏មិនមានផ្លូវដែលអាចនឹងពុះដល់ត្រឹមសោតាបន្ន ជនពួកនេះគួរទូន្មានឲ្យរំពឹងមើលយ៉ាងនេះថា ក្នុងលោកនេះ មានអ្នកណាខ្លះដែលឡើងទៅកាន់ទីខ្ពស់បាន ដោយមិនបាច់ជាន់កាំជណ្ដើរតាមជាមុននោះ; ក្នុងផ្លូវធម៌ក៏ដូចគ្នា បើមិនសិក្សា មិនបំពេញធម៌ក្នុងជាន់ទាប ៗ ជាមុនទេ ក៏មិនអាចនឹងសម្រេចដល់ធម៌ជាន់ខ្ពស់បានឡើយ ។ ការលះសេចក្ដីព្យាយាមចោលចេញនោះ នឹងស្វែងរកគុណប្រ-យោជន៍មិនបានឡើយ សូម្បីតែប្រយោជន៍ស្មើនឹងខ្លួនក៏មិនបានដែរ រមែងបានជួបតែនឹងផលអាក្រក់ប៉ុណ្ណោះ, ព្រោះកិលេសដែលត្រាប់ផ្គាត់ក្នុងចិត្តរបស់យើង រមែងតាមបញ្ជាឲ្យយើងធ្វើតាមចិត្តរបស់ខ្លួន ។

មែនពិត បាបកម្ម រមែងធ្វើបានងាយជាងបុញ្ញកម្ម ដូចនោះការលុះក្នុងអំណាចចិត្តរបស់ខ្លួន អាចនាំយើងឲ្យធ្វើបាបកម្មរឿយ ៗ ។ តែបើមានសេចក្ដីព្យាយាមខ្លះខ្នែង សាប ព្រោះបណ្ដុះដាំពូជកុសលធម៌ទុកក្នុងសន្ដាន ល្អហើយ ន័យនេះ ប្រៀបដូចជាប្រទេសបានកេណ្ឌទាហាន ជាកងទ័ព យ៉ាងស្ថាបនា សម្រាប់បង្ក្រាបបាបធម៌ដែលទុកដូចជាបច្ចាមិត្រដូច្នោះឯង ។

ការញាំញីកិលេសរបស់យើងជាករណីយកិច្ច មិនចំពោះតែខ្លួនយើងប៉ុណ្ណោះទេ ទាំងជាករណីយកិច្ចដែលយើងគួរប្រព្រឹត្ត ដើម្បីជាប្រយោជន៍ដល់មិត្រ រួមជាតិផង រួមសាសនាផង រួមប្រទេសផង ។

មនុស្សយើង សូម្បីសញ្ជាតិណា ឬកាន់សាសនាណាក៏ដោយ រមែងមិនពេញចិត្ត មិនទុកចិត្តចំពោះបុគ្គលដែលទ្រុស្តធម៌ ព្រោះបុគ្គលទ្រុស្តធម៌ប្រៀបដូចជាសត្វព្រៃដ៏សាហាវ ដែលមិនដឹងថានឹងប្រទុសរ៉ាយដល់បុគ្គលណាក្នុងកាលណាមួយឡើយ តែរមែងជាទីរង្កៀសសង្ស័យជានិច្ច; ដូចនោះបើប្រាថ្នាសេចក្ដីសុខស្ងប់ដល់ពួកមនុស្ស ជារត្នដែលយើងចង់បានពិត ៗ យើងត្រូវប្រព្រឹត្តខ្លួនឲ្យតាំងនៅក្នុងសីលធម៌ ដើម្បីបើកឱកាសឲ្យមិត្តរួមជាតិសាសនា-ប្រទេស លូកដៃចូលមកសេពគប់បានដោយប្រាសចាកសេចក្ដីរង្កៀសចិត្ត ។

ការប្រព្រឹត្តខ្លួនឲ្យតាំងនៅក្នុងសីលធម៌នោះត្រូវតែមានលក្ខណៈ ដែលអាចទាញចិត្តឲ្យតាំងនៅមាំក្នុង "សទ្ធា" នឹងត្រូវមានគ្រឿងដាស់តឿនចិត្តឲ្យជ្រះថ្លានូវការស្វែងរកសេចក្ដីបេះដឹងក្នុងផ្លូវធម៌ ។ របស់អ្វីក្នុងលោកនេះ ដែលល្អជាងប្រសើរជាងព្រះរតនៈត្រៃ? ព្រោះហេតុអ្វីទើបដូច្នោះ? បានជាដូច្នោះ ព្រោះហេតុថា: ព្រះពុទ្ធជាម្ចាស់ត្រាស់ដឹងនូវព្រះធម៌, ឯព្រះធម៌នោះ គឺព្រះសង្ឃបានទ្រទ្រង់ទុក, ហើយព្រះសង្ឃក៏ជាសាវករបស់ព្រះពុទ្ធជាម្ចាស់ ។ ព្រះរតនៈត្រៃនេះ ជារត្នហ្មត់ចត់ ឧត្តុង្គឧត្តមប្រសើរលើសលប់ជាងរតនៈក្នុងលោក រមែងជាទីប្រព្រឹត្តទៅព្រម ដើម្បីសេចក្ដីផូរផង់យ៉ាងក្រៃលែងដល់សត្វទាំងឡាយអ្នកជ្រះថ្លា ហើយអាចញ៉ាំងសេចក្ដីហ្មត់ចត់យ៉ាងផូរផង់ ដល់ខ្លួនអ្នកបដិបត្តិដោយពិត ៗ បុគ្គលណាបានដល់ព្រះរតនៈត្រៃជាសរណៈនោះហើយនឹងអាចឃើញនូវអរិយសច្ចទាំង ៤ ដោយបញ្ញាដ៏ពិតហើយបុគ្គលនោះ រាប់ថា បានកប់ប្រសព្វនឹងសរណៈនោះដែលធ្វើឲ្យសប្បាយរីករាយចិត្តយ៉ាងក្រៃលែង ព្រោះអ្វី? ព្រោះអាចនឹងធ្វើឲ្យផុតស្រឡះរួចចាកសេចក្ដីទុក្ខទាំងពួងបាន ដូចពោលនេះឯង ។

បណ្ឌិត សម-សុខុម

# ដំណឹងសាសនា

## បុណ្យកតញ្ញូកតវេទី

## ចំពោះសម្ដេចព្រះធម្មលិខិតឧត្តមប្រឹក្សាគណមហានិកាយ (ត)

មានសេចក្ដីដូចតទៅ ៗ

សូមគោរពចំពោះសម្ដេចទាំងពីរព្រះអង្គជាសង្ឃបិតា !

សូមគោរពចំពោះព្រះថេរានុថេរទាំងឡាយ !

សូមឱកាសអស់លោក អ្នកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំប្របាទ ខ្ញុំបាទខ្ញុំ ជាតំណាងពុទ្ធបរិស័ទ នឹងសិស្សានុសិស្ស របស់សម្ដេច សូមថ្លែងសេចក្ដីពិតជាសច្ចវាចា ដើម្បីរំលើកបើកកកាយយកកាតផល នៃការកុសលរបស់សម្ដេច ដែលបានធ្វើកន្លងទៅហើយ យកមកពូតផ្គុំផ្សំជាមួយគ្នា នឹងផលនៃការកុសលបច្ចុប្បន្ននេះ ប្រគេនចំពោះសម្ដេច ជាសង្ឃបិតា ក្នុងវេលា ដែលសម្ដេច មានជរាពាធប្រចាំកាយ ៗ

បពិត្រសម្ដេចជាទីគោរព !

យើងខ្ញុំទាំងឡាយ ទាំងគ្រហស្ថ ទាំងបព្វជិត ខ្លះជាសិស្សានុសិស្ស ខ្លះជាឧបាសកចំណុះវត្តនេះ ខ្លះជាញាតិមិត្ត មានសេចក្ដីស្រឡាញ់នឹងសេចក្ដីគោរពដោយពិតចំពោះសម្ដេច ដែលជាឧត្តមបុរសមួយអង្គក្នុងប្រទេសកម្ពុជា ព្រោះយើងខ្ញុំដឹងពិតថា សម្ដេចប្រកបដោយគុណទាំង២ប្រការគឺៈ

ឧបការគុណ១ នេមិត្តិកគុណ១ ។

ព្រះគុណទី១ ដែលហៅថាឧបការគុណ គឺសម្ដេចប្រកបដោយ ព្រហ្មវិហារធម៌ បានដល់មេត្តា, ករុណា, មុទិតា, ឧបេក្ខា, ។

យើងខ្ញុំទាំងឡាយ បានសង្កេតឃើញពិតថា សម្ដេចមានធម៌ទាំង៤ប្រការនេះ ពេញលេញក្នុងព្រះអង្គមែនៗ ព្រោះកាលដែលសម្ដេចទើបនឹងបានឧបសម្បទា សម្ដេចបានគ្រប់គ្រងភិក្ខុសង្ឃសាមណេរនៅវត្តស៊ីធរក្ដី កាលពី ព. ស. ២៤៥៤ ដរាបមកដល់ឥឡូវនេះ សម្ដេចបានគ្រប់គ្រងភិក្ខុសង្ឃ សាមណេរក្នុងវត្តលង្កានេះ ដែលមានភិក្ខុសាមណេរ ដ៏ច្រើនលើសលុបក្ដី សេចក្ដីរកាំរកូសក្នុងសង្ឃមណ្ឌល ពុំដែលមានដល់ម្ដងសោះ ។ សេចក្ដីសុខដ៏ធំទូលាយ ដែលកើតឡើងក្នុងមហាសង្គមយ៉ាងនេះ តាមរឿងក្នុងគម្ពីរថា ប្រាកដជាកើតឡើង ដោយសារព្រហ្មវិហារធម៌ នៃប្រមុខរបស់សង្គម ។



ក្រុមសាស្ត្រាចារ្យ និងសមណៈនិស្សិតនៅវិជ្ជាស្ថាននាលន្ទា, ឥណ្ឌៀ ។
សមណៈនិស្សិតទាំងនេះ មកពីប្រទេសផ្សេងៗគ្នា គឺ លង្កា, ខ្មែរ, សៀម, លាវ, យួន, ទីបេត៍, នឹងជប៉ុន ។

ខនេះ បើនិយាយឲ្យចំៗទៅថា កាលដែលវត្តលង្កា នៅក្នុងផ្ទៃបឹងដ៏ជ្រៅ មានលំនៅភិក្ខុសង្ឃសុទ្ធតែជាកូបតូចៗបន្តបន្ទប់ យើងខ្ញុំទាំងឡាយ ជាសិស្សក្នុងជំនាន់នោះ បានទទួលសេចក្តីប្រោសប្រណី អំពីសំណាក់សម្តេច ឥតបើគណនា គឺសម្តេចបានទទួល ឲ្យយើងខ្ញុំគ្រប់គ្នា នៅក្នុងទីអារាមនេះ ដោយឥតរើសមុខ ថាកូនអ្នកមានឬក្រ ថាកូនអ្នកក្រុងឬអ្នកស្រែ-ចំការឡើយ លើកលែងតែមនុស្សដែលជាទីរង្កៀសចេញ សម្តេចបានប្រឹងប្រែងកសាងវត្តនេះ ដើម្បីជាទីលំនៅយើងគ្រប់គ្នាដោយឥតសំចៃព្រះកាយពលដរាបតែវត្តនេះ ប្រាកដជាអារាមមួយយ៉ាងធំ ក្នុងទីកណ្តាលរាជធានីខ្មែរ, សព្វៗកាល សម្តេចបានចែកសង្ឃលាភ ឲ្យភិក្ខុសាមណេរឥតរើសមុខ មិនឲ្យលើសខ្វះ, វេលាជិតចេញវស្សាក្រោយពេលដែលឲ្យយើងខ្ញុំជាសិស្ស សិក្សាធម្មវិន័យច្រើនខែ ហើយសម្តេចតែងចាត់ការឲ្យប្រឡងសាកមើល ដើម្បីប្រទានស្បង់ចីពរនិងវត្ថុផ្សេងៗ ជារបស់ផ្ទាល់ព្រះអង្គ ទោះថោកថ្លៃ តិចច្រើន ដល់សិស្សដែលប្រឡងជាប់លេខទាបខ្ពស់តាមលំដាប់, រាល់ៗឆ្នាំរៀងមក អស់រយៈកាលជាអង្វែង សម្តេចបានបង្ហាត់បង្រៀនគម្ពីរបាលី ធម្មវិន័យ ព្រមទាំងប្រទានឧវាទ ជាប្រក្រតីផ្ទាល់ព្រះអង្គផង ចាត់ឲ្យជួយបង្ហាត់បង្រៀនថែមទៀតផង ។

ករណីយកិច្ចដ៏ថ្លៃថ្លាទាំងនេះ ប្រាកដជាផុសចេញអំពីព្រហ្មវិហារធម៌ គឺថាព្រោះតែសម្តេចមានព្រហ្មវិហារធម៌ ទើបបំពេញករណីយកិច្ចដ៏ប្រសើរទាំងនេះបាន ដែលចាត់ជាឧបការគុណដ៏ធ្ងន់ មកលើយើងខ្ញុំគ្រប់គ្នា ។

ទី ២ ដែលថាសម្តេចប្រកបដោយនេមិត្តកគុណ គឺគុណដ៏អស្ចារ្យ បានដល់កិត្តិសព្ទ កិត្តិនាមដ៏ល្បីល្បាញ ដែលផុលផុសដុះចេញផ្សាយទៅអំពីសមត្ថភាពរបស់



សមណៈនិស្សិតខ្មែរយើង៣អង្គកំពុងសូត្រធម៌នមស្ការ បូជា ក្រោមដើមពោធិព្រឹក្សដាទីដែលព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ ផ្សាយតាមរលកធាតុអាកាសឥណ្ឌៀ នៅពេលបុណ្យពុទ្ធជយន្តិរំលឹកដល់អាយុកាលនៃពុទ្ធសាសនាជាគំរប់ ២.៥០០ ព្រះវស្សា ។

សម្តេច ជួបខ្ញុំព្រះករុណានិទានរៀបរាប់តទៅ ។

ក) កាលសម្តេចទើបនឹងបានឧបសម្បទាថ្មីៗ ក្នុង ព. ស. ២៤៤៣ សម្តេចព្រះមហាសង្ឃរាជព្រះនាមទៀន បានតាំងសម្តេចជា អាចារ្យបង្ហាត់សូត្រធម៌ភាណវារបាលី ឲ្យប្រើឲ្យល់ទីឃៈរស្សៈ វែងខ្លី ត្រឹមត្រូវតាមវិធីភាសាបាលី ក៏ព្រោះតែសម្តេចពោះបីជិតនៅក្នុងបឋមវ័យសោះទេ ប៉ុន្តែស្ទាត់ជំនាញក្នុងការនេះ គ្រាន់បើជាងគេ ។

ខ) កាលពី ព. ស. ២៤៤៥ សម្តេចព្រះមហាសង្ឃរាជ បានតាំងសម្តេចជាចៅអធិការវត្តសុធរ ក៏ព្រោះតែសម្តេច មានសមត្ថភាពខាងការបង្ហាត់បង្រៀនធម្មវិន័យផង ខាងការគ្រប់គ្រងពួកគណៈផង ។

គ) កាលពី ព. ស. ២៤៥៨ ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស

កាលនៅជាព្រះអនុម្ចាស់អធិបតីនៅឡើយ បានពិគ្រោះព្រមព្រៀងជាមួយនឹងសម្តេចព្រះមហាសង្ឃរាជ នឹងព្រះសពព្រះមហាវិមលធម្ម ថោង បាននិមន្តសម្តេចពីវត្តស៊ីធរ មកតាំងជាចៅអធិការវត្តលង្កានេះ ក៏ព្រោះតែសម្តេច មានសមត្ថភាព ហើយបានធ្វើការមានថ្វីព្រះហស្ត តាំងពីទើបនឹងបានឧបសម្បទាថ្មី ៗ មកម៉្លេះ ។

ឃ) កាលពី ព. ស. ២៤៥៦ សម្តេចបានសមណស័ក្តិ ជាព្រះគ្រូវិមលបញ្ញា, កាលពី ព. ស. ២៤៥៧ សម្តេចបានឡើងសមណស័ក្តិជាព្រះញាណបវរវិជ្ជា រាជាគណៈក្នុងដំណែង ក៏ព្រោះតែសម្តេច មានសមត្ថភាព អាចជ្រោងវត្តលង្កា ដែលឋិតនៅក្នុងផ្ទៃបឹងដ៏ជ្រៅ មានសេនាសេនៈ វេខករោគ ឲ្យឡើងជាអារាមមួយដ៏រុងរឿង តាំងជាវត្តដែលមានភិក្ខុ សាមណេរ បួនប្រាំអង្គ ឲ្យបានទៅជាអារាម មានភិក្ខុសង្ឃកុះករដល់ប្រាំមួយប្រាំពីររយអង្គ ។

ង) កាលពី ព. ស. ២៤៥៨ សម្តេចបានឋានៈជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ក៏ព្រោះតែមានសមត្ថភាពខាងការចេះដឹង អាចប្រឡងយកឋានៈនោះបាន ។

ច) កាលពី ព. ស. ២៤៧២ សម្តេចបានឡើងឋានៈជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ ហើយតមកបានជាអធិបតីក្រុមជំនុំព្រះត្រៃបិដកទៀត ក៏ព្រោះតែសម្តេច អាចត្រួតត្រាក្នុងការសិក្សាផ្លូវព្រះពុទ្ធសាសនាបាន ។

ឆ) តាំងពីត្រឹមណោះដរាបមក សម្តេចបានផ្តើម ប្រែព្រះត្រៃបិដក, បានចាត់ការឲ្យសរសេរចម្លងបាលី ព្រះត្រៃបិដក, សម្តេចបានរួមប្រជុំ ក្នុងការជំនុំបង្កើតពុទ្ធ-សាសនាបណ្ឌិត្យ, បានផ្តើមគំនិតបង្កើត សាលាបាលីរង ក្នុងសកលកម្ពុជរដ្ឋ ព្រមទាំងជាគ្រូប្រឹក្សា ក្នុងការបង្កើតពុទ្ធសាសនបណ្ឌិត្យរង នឹងសាលាបាលីរង នៅប្រទេស

លាវនឹងប្រទេសកូសាំងស៊ីនផង, បានទទួលចាត់ការរៀបផ្ចាត់បង្រៀន ពួកសមណនិស្សិត ពីប្រទេសលាវនឹងប្រទេសកូសាំងស៊ីន ។ ដោយហេតុសម្ដេចមានករណីយដ៏ប្រសើរទាំងនេះ ទើបសម្ដេចបានឡើងសមណស័ក្ដិ ជាព្រះសិរីសម្មតិវង្ស, ជាព្រះធម្មលិខិត, ជាសម្ដេចព្រះធម្មលិខិត ឧត្ដមប្រឹក្សា ព្រមទាំងបានគ្រឿងឥស្សរិយយសដ៏ខ្ពង់ខ្ពស់ តាំងពីមេដៃយ មុនីសារាភ័ណ រហូតដល់មេដៃយអស្សរិទ្ធិ ក្រុមដូណើរ ដែលបារាំង ហៅថា ស៊ីវ៉ាលីយេរ៉ដឺឡាឡេស្យ៉ុងដូណើរ ។

គុណដ៏អស្ចារ្យ ដែលផុសផុះចេញអំពីសមត្ថភាព យ៉ាងនេះ ហៅថា នេមិត្តកគុណ ។ (នៅមានត)

---

## ស្ថានការណ៍នៅសហភាពភូមា (ត)

ស្រេចហើយនៅសាប៊ូគឺគ្រាន់តែង៉ូតទឹកជម្រះរាងកាយដោយសាប៊ូទុកជាការស្រេច ៗ ម្យ៉ាងទៀត មិនសូវនិយមប្រើខ្សែមាសទាំងចង្វាយឬពេជ្រទាំងគ្រាប់ ៗ ទេព្រោះគេយល់ថាជាការលំបាក គេនិយមប្រើខ្សែកឬក៏ខ្សែដៃដែលរចនាអំពីទង់ហ្វា អំពីប្រាក់ទៅវិញ ៗ បើដូច្នេះយល់ថាប្រជាជនប្រទេសនោះក្រខ្សត់ណាស់ឬដូចម្ដេចឆ្លើយថា មិនមែនដូច្នោះទេតាមដោយពិត ការនេះជាធម្មតាទេគឺថាគ្រប់ប្រទេសក្នុងសកលលោក តែងមានមនុស្សអ្នកមានទ្រព្យច្រើន, ធុនកណ្ដាលក្រខ្សត់ដូចគ្នា មិនមែនសុទ្ធតែអ្នកមានឬអ្នកក្រឡើយ ៗ ចុះហេតុដូចម្ដេចបានជាគេមិននិយមប្រើ ? ឆ្លើយថាព្រោះគេសំចៃប្រាក់កាសទុកប្រកបកិច្ចការផ្សេង ៗ ទៀត ៗ ម្យ៉ាងទៀតដោយយល់ឃើញថា បើមានប្រាក់កាសច្រើនហើយទិញខ្សែកដែលវិចិត្រដោយមានពេជ្រផ្សេង ៗ ពាក់សំញែងសព្វាទៅណា

មកណាច្រើនប្រកបដោយការគ្រោះថ្នាក់ផ្សេង ៗ ព្រោះហេតុនោះ បានជាគេមិននិយមប្រើទៅវិញ ។ ឯការលាបលនបំពូនកងកាយ គេនិយមប្រើលំអិតខ្វីមច័ន្ទន៍ ស ក្រហមទៅវិញ ព្រោះគេយល់ថាវត្ថុនេះត្រជាក់ហើយថ្លៃថោកផង ។

៧– អំពីការអត់ធ្មត់និងការអត់ទោសទោសា:- ប្រជាជនភូមា មានការអត់ធ្មត់និងការអត់ទោសចំពោះអធិករណ៍ ការគ្រោះថ្នាក់ ដែលឧប្បត្តិឡើងដោយហេតុអ្វីមួយ ៗ រវាងជនដែលមានសញ្ជាតិដូចគ្នាណាស់ តួយ៉ាងមានការនិយាយពាក្យឈ្លើសឈ្លងគ្នាទៅវិញទៅមកក្តី មានការប៉ះទង្គិច ឬដល់ប៉ះគ្នាដោយរាងកាយក្តី ដោយត្រីចក្រយានឬរថយន្តផ្សេងៗ ក្តី គេពុំដែលឃើញជេរឬវាយប្រតប់គ្នាឡើយ ។ បើប្រសិនជានរណាខុសក៏សូមការអត់ទោសអំពីសំណាក់អ្នកត្រូវ , បើជាប៉ះទង្គិចទៅហើយមានការខូចខាតត្រូវជួយចេញសោហ៊ុយគ្នាជួយជួសជុលរបស់នោះៗ ឲ្យបានស្អាតល្អឡើងវិញប៉ុណ្ណោះ ។ ម្យ៉ាងទៀតគេពុំដែលជួបប្រទះជាតិភូមាជេរប្រទេចផ្តាសា ឬដល់តប់គ្នាក្នុងទីប្រជុំជនដូចជាកណ្តាលផ្សារផ្សាឡើយ បើមានហេតុគួរដល់ការក្រោធខឹង គ្រាន់តែជជែកគ្នាឲ្យឃើញការខុសត្រូវទៅវិញទៅមកហើយភ្លើសំឡេងពុស្សូរតក់ ៗ (ក្តក់) ១.២.៣. ដងប៉ុណ្ណោះទុកជាការស្រេច ។

៨– អំពីការស៊ី - ផឹក - ប្រជាជនជាតិភូមា គមមិនជក់អាភៀនកញ្ឆា ឬផឹកស្រានិងទឹកត្នោតជូរឡើយ ។ នៅតាមតម្បន់និគមជនបទទូទៅទាំងប្រទេស ទោះបីតាមចន្លោះផ្សារផ្សាតូចធំក្តីតាមប្រកល្ហក ឬតែមច្នល់កៀនកោះឯណានិមួយក្តី តែគេពុំដែលឃើញសញ្ជាតិភូមាណាម្នាក់ លក់ស្រាឬទឹកត្នោតជូរសោះឡើយ ព្រោះរដ្ឋាភិបាល ហាមប្រាមដាច់ខាតមិនឲ្យមានជំនួញដោយគ្រឿងស្រវឹងផ្សេង ៗ ។ មិនតែប៉ុណ្ណោះចំពោះល្បែង

ស៊ីសងគ្រប់យ៉ាង ដូចជាបៀរអាប៉ោងធ្វើជាដើមដែលជាហេតុនាំឲ្យវិនាសទ្រព្យសម្បត្តិ នាំឲ្យខូចចិត្តឬក៏ក្តៅក្រហាយចិត្ត នឹងជាហេតុបណ្តាលឲ្យកើតអធិករណ៍ផ្សេងៗ ទៀត ៗ ព្រោះគេយល់ថាការបើកសិទ្ធិសេរីភាពឲ្យលេងល្បែងស៊ីសងគ្រប់យ៉ាងក្តី ឲ្យលក់ស្រាអគៀនកញ្ឆាទឹកត្នោតជូរក្តី ជាហេតុនាំឲ្យកើតអធិករណ៍ នាំឲ្យវិនាសហិនហោចទ្រព្យសម្បត្តិគេក្តី ឈ្មោះយេសសក្តិនៃពលរដ្ឋ ព្រោះថាជនណាបណ្តោយខ្លួនឲ្យលុះក្នុងអំណាចនៃអំពើអវមង្គល ដ៏សាហាវយង់ឃ្នងបែបនេះនឹងក្លាយខ្លួនទៅជាអ្នកលេងអ្នកលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃផង ជាហេតុផ្តាច់បង់នូវភោគសមដ្ឋានផ្សេង ៗ ផង ៗ

៩– អំពីគេហស្ថានផ្ទះសម្បែង៖ នៅគ្រប់តំបន់ក្នុងស្រុកនិគមជនបទនានាក្នុងសហភាពភូមា កាលបើមានគេហស្ថាន ត្រូវមានបង្គន់ជាដាច់ខាត ព្រោះគេយល់ថាកាលបើគ្មានបង្គន់សម្រាប់បន្ទោរបង់លាមកជាហេតុបណ្តាលឲ្យកើតរោគផ្សេង ៗ ម្ល៉ោះហើយរាជការរៀបចំផ្ទះសម្បែង ឲ្យដាច់ស្រឡះពីគ្នាមានទំណាររបងស៊ីម៉ងត៍ឬឈើដោយឡែក ៗ ពីគ្នា ៗ នៅខាងមុខនៃគេហស្ថាននីមួយ ៗ ចំផ្លូវចេញ - ចូលសុទ្ធតែមានអក្សរចារឹកឈ្មោះសាមីគេហស្ថាននៅលើផ្ទាំងក្តារ ១ ផ្ទាំងប្រវែងមួយម៉ែត្រឬ ២ - ៣ - ម៉ែត្រតាមបំណងអ្នកម្ចាស់ផ្ទះ ៗ

៩– អំពីអាពាហ៍ពិពាហ៍៖ នៅប្រទេសភូមា មានកិច្ចធ្វើអាពាហ៍ពិពាហ៍មង្គលការ ២ ផ្នែកគឺ គឺផ្នែកទី ១ មានកិច្ចទៅដណ្តឹងកូនស្រីតាមទំនៀមទម្លាប់ប្រហែលនឹងទំនៀមទម្លាប់នៅប្រទេសខ្មែរយើងដែរ ៗ ផ្នែកទី ២ មានកិច្ចអាពាហ៍ពិពាហ៍ តម្រូវតាមបំណុះចិត្តនឹងអធ្យាស្រ័យនៃបុត្រធីតា គឺថាបុត្រធីតាទាំងសងខាងអាចស្គាល់ទឹកចិត្តគំនិតអធ្យាស្រ័យនឹងសមត្ថភាពព្រមទាំងពូជពង្សវង្សត្រកូលទៅវិញទៅមកជាមុនបានសេចក្តីថា បើ

បុរសឬស្ត្រីរូបណាបាននិយាយចរចារគ្នាទៅវិញទៅមក នឹងធ្លាប់រាប់អានគ្នាធ្លាប់ទុកចិត្តគ្នាធ្លាប់បានផលប្រយោជន៍ដល់គ្នា ស្គាល់អធ្យាស្រ័យរវាងគ្នានឹងគ្នាជាប្រថមនោះ បុរសនឹងស្ត្រីទាំងពីរនាក់ នាំគ្នាទៅចុះអេតាស៊ីវិលរួចស្រេច ទើបជំរាបឪពុកម្ដាយ បងប្អូនញាតិមិត្រទាំងសងខាងឲ្យរៀបមង្គលការដល់ខ្លួនជាខាងក្រោយ ។

បានជារៀបចំមង្គលការបែបនេះ ព្រោះគេយល់ថា បើឪពុកម្ដាយទាំងសងខាងរៀបចំបុត្រធីតាឯណានីមួយ ដែលកូនប្រុស-ស្រីរបស់ខ្លួន ពុំធ្លាប់ស្គាល់ចិត្តថ្លើមនឹងអធ្យាស្រ័យព្រមទាំងពុំបានទុកចិត្តគ្នាទៅវិញទៅមកទេ ប្រាប់តែឃើញគ្នាម្ដងម្កាលហើយផ្គុំឲ្យជាស្វាមីភរិយាតែម្ដងទៅ សេចក្ដីសុខសាន្តក្ដីមេត្រីភាពរវាងគ្នានឹងគ្នាពុំបានជិតស្និទ្ធ ម៉្លោះហើយឪពុកម្ដាយទាំងសងខាងអនុលោមកិច្ចធ្វើអាពាហ៍ពិពាហ៍ទៅតាមអធ្យាស្រ័យ នៃបុត្រធីតា ។ បានជាគេនិយមធ្វើកិច្ចនេះដូច្នេះ ព្រោះថា ឪពុកម្ដាយបុរសខ្លះ ៗ គាប់ចិត្តអធ្យាស្រ័យនៃធីតាឯណានីមួយ ដោយចង់ផ្សំផ្គុំធីតានោះ ៗ ដល់បុត្ររបស់ខ្លួនតែបុត្ររបស់ខ្លួនពុំគាប់ចិត្ត ពុំដែលស្គាល់គ្នាដោយជាក់លាក់ទៅវិញទៅមក ជួនកូននោះប្រថុយតាមដំបូន្មានឪពុក-ម្ដាយរបស់ខ្លួន ខ្លះក៏ពុំព្រមសុខចិត្តតាម ។ ខ្លះពុំទាន់បានរៀបចំអាពាហ៍ពិពាហ៍ផង កូននោះក៏លបរត់បាត់ទៅ, ខ្លះបានពីរបីថ្ងៃ ឬពីរបីខែរត់ចោលគ្នាទៅក៏មាន ខ្លះចងកសម្លាប់ខ្លួន, ខ្លះលោតខ្លួនទៅក្នុងទឹកក៏មាន មកពីការរៀបចំមង្គលការ ពុំសមតាមបំណង, ខ្លះទៀតទម្រាំនឹងចុះសម្រុងគ្នា ស្គាល់ចិត្តគ្នា នឹងទុកចិត្តគំនិតគ្នា អស់រយៈកាល១ខែឬពីរបីខែ ឃើញថាជាការពិបាកណាស់ដែរ ។

ចុះបើគេបណ្ដោយបុត្រធីតាដោយប្រការបែបនេះក្រែងចួសខ្លួនមុនមង្គលការទេដឹង?ៗ ឆ្លើយថាការណ៍នេះជាធម្មតាទេ, ខ្លះក៏ចួសខ្លួនមុនធ្វើមង្គលការក៏មាន. ខ្លះធ្វើមង្គលការ

រួចហើយពុំបានចុស់ខ្លួនក៏មាន, (នេះមកពីហេតុអ្វី?... ៗ តែថា ប្រជាជនប្រទេសកូមា មានការហាមប្រាមដល់បុត្រធីតាដោយតឹងរ៉ឹងណាស់ គឺគេហាមមិនឲ្យប្រព្រឹត្តអានាចារ ដល់កាន់កាយជាដាច់ខាត ៗ កាលបើបុរសរូបណាប្រព្រឹត្តល្មើសចំពោះលើស្ត្រីរូបណា បុរសរូបនោះត្រូវមានទោសជាទម្ងន់ ៗ ម្យ៉ាងទៀតប្រជាជនសហភាពកូមា ទោះជាបុរសក្តីស្ត្រីក្តី មិនសូវមានការរួញរាសូញសាញ ការអៀនខ្មាស ការអំអៀនទេ ច្រើនតែជាអ្នកអង់អាចប្រសប់ខាងការនិយាយស្តី មិនអៀនខ្មាសចំពោះហេតុគេទដែលមិនគប្បីអៀនខ្មាស មិនកោតញញើតប្លុកខ្លាចចំពោះហេតុការណ៍ដែលមិនគួរញញើតញ-ញើមឬខ្លបខ្លាច គឺឥសភាពស្ត្រី មានសមត្ថភាពនឹងសិទ្ធិ អាចនិយាយចរចា ជជែកការណ៍ ថ្លែងការណ៍ ធ្វើការ សរសេរកត់ត្រាហេតុគេទផ្សេង ៗ ប្រហែលគ្នានឹងសភាពបុរសដែរ ៗ ពិតមែនតែសហភាពកូមា បានឯករាជ្យអស់រយៈកាលដ៏ខ្លី៨ឆ្នាំផ្ទាយប៉ុណ្ណោះ តែថាប្រទេសឯករាជ្យ ប្រជាជនក៏ឯករាជ្យ សិទ្ធិគ្រប់យ៉ាងក៏ឯករាជ្យដែរ ៗ

(នៅមានត)

---

## សេចក្តីរាយការណ៍អំពីការប្រជុំនៃគណៈកម្មាធិការ ទីប្រឹក្សាពុទ្ធគយា ថ្ងៃទី ១៩ មីនា ១៩៥៦ (ត)

នរណាមួយជាអ្នកកាន់សាសនា មិនមែនអាចធ្វើអ្នកនោះឲ្យទៅជាអ្នកកាន់សាស-នា ពិតដូចពាក្យនោះទេ « លុះត្រាតែយើងមានការប្រតិបត្តិសព្វគ្រប់ ទើបយើងនឹងអាចបានឈ្មោះថា ជាអ្នកកាន់សាសនាពិតប្រាកដមែន » ៗ វិបស្សនាកម្មដ្ឋាន ជាចម្លើយតែមួយចំពោះរឿងនេះ ដ្បិតក្នុងបច្ចុប្បន្នសម័យ យើងឃើញជាក់ច្បាស់ថា ប្រ-

ជាជនកំពុងល្ងក់ដោយការរីករាយសប្បាយក្នុងកាមពន់ពេក ។ មនុស្សដែលនឹងទៅជាអ្នកជំប្រសើរបានលុះតែដើរម្នាក់ឯង ពុំមែនដើរដោយពួកដោយក្រុមឡើយ ។ លោកបានបញ្ចប់សេចក្តីដោយថ្លែងយោបល់ថា យើងគប្បីតែដោះស្រាយសេចក្តីលំបាកព្រោះកង្វល់នៃពិភពលោកបានខ្លះ ទើបសមឋានៈដែលនឹងធ្វើពិធីបុណ្យសម្ពោធពុទ្ធសករាជគំរប់ ២៥០០ ហើយបើយើងទាំងអស់គ្នា មានគោលបំណងតែមួយនេះយើងមិនត្រូវទាស់ទែងខ្វែងគំនិតគ្នារវាងសាសនាឡើយ ។ល។

នៅទីបំផុត អ្នកស្រីសរីមតីលក្ស្មីមេន័ន ជាសមាជិកានៃរដ្ឋាភិបាលពិហារ បានបញ្ចេញមតិថ្លែងអំណរគុណ ចំពោះលោកអនុប្រធានាធិបតី ហើយបានពោលអំពីការរួបរួមនៃសាសនាផង ។

បន្ទាប់មកមានការផ្អាកពេលប្រជុំ ដោយមានមគ្គុទេសក៍ណែនាំសមាជិក នៃគណៈកម្មាធិការទៅពិនិត្យមើលដល់ទីកន្លែងក្នុងមណ្ឌលពុទ្ធគយា ហើយទើបមានការជប់លៀងភោជនាហារ ។

ការប្រជុំបានចាប់ផ្តើមម្តងទៀត នៅវេលាម៉ោង ១៤ ក្នុងថ្ងៃមួយនោះ សមាជិកទាំងអស់បានពិភាក្សាជ្រើសតាំងប្រធាន ។ អ្នកស្រីសរីមតីលក្ស្មីមេន័នបានសុំតែងតាំងលោកអេឌ្វិនវិជយរត្ន ; ប្រតិភូលង្កាទ្វីប ហើយដោយពុំមានការសុំតែងតាំងដទៃទៀត លោកក៏ព្រមទទួល នាទីជាប្រធាន ។

ដំបូងលោកប្រធានបានពិនិត្យបញ្ជីរាយនាមអ្នកតំណាងគ្រប់ប្រទេស ដែលបានមកកាន់ទីប្រជុំដូចតទៅនេះ ៖

(១) លោកស៊ើ អ៊ូ អនតេ ប្រទេសភូមា ;

(២) លោកស៊ើ អ៊ូ សានញ៉ុង ប្រទេសភូមា (ពុំបានមក)

(៣) ភិក្ខុ ប៉ុណ្យ-សម្ដាជ ធម្មាពម ប្រទេសកម្ពុជា ;

(៤) លោក អេ ឌ្វីនវិជយរត្ន លង្កាទ្វីប ;

(៥) លោក ស៊ើ តៅតុដ្ឋ ប្រទេសចិន ;

(៦) ភិក្ខុ ចៀន ប៉ៃចិនលៀះ ប្រទេសចិន ;

(៧) លោក ស៊ើ កូសូ-អូថានី ប្រទេសជប៉ុន (ពុំបានមក)

(៨) ឯកឧត្ដម ពញាខាំមៅ ប្រទេសលាវ (ពុំបានមក)

(៩) ភិក្ខុអម្រឹតានន្ទៈ ប្រទេសនេប៉ាល់ ;

(១០) ឯកឧត្ដមព្រះពហិទ្ធនុករ ប្រទេសថៃ ,

(១១) ព្រះមហាពជកុមារ ប្រទេសសិក្គិម ;

(១២) លោកស៊ើកុស៊ាក ពទុលៈ ;

(១៣) អ្នកស្រី ស៊ើមតី លក្ស្មើទន សមាជិកាសភា ;

(១៤) លោកស៊ើ ត. រ័ង្គ័ ;

(១៥) លោកស៊ើ ន.ជ. ឃារួ

(១៦) លោកកុមារ គង្គានន្ទ សិង្ហ ; M. L. C. ;

(១៧) លោកស៊ើ ជក់ស ឆៅព្រ៊ ; M.L.A. ;

(១៨) លោកស៊ើ រាមេស្វរ ប្រាសាទសិង្ហ ; M.L.C. ;

(១៩) លោកបណ្ឌិត ប៉.ល. វៃទ្យៈ ;

(២០) លោកលេខាធិការ បក្រកតអមរដ្ឋាភិបាលឥណ្ឌា, ក្រសួងការបរទេស (ពុំបានមក) ។

(២១) លោកអគ្គនាយកនៃបុរាណវត្ថុវិជ្ជាក្នុងប្រទេសឥណ្ឌា (ពុំបានមក)

(២២) លោកអធិការី តំបន់បត្នៈ (ពុំបានមក) ។

បណ្ដាសមាជិក ១៤ រូបដែលមកជួបជុំខាងលើនេះ មានតែសមាជិក ៨ រូបទេ ដែលពុំមែនជាជនជាតិឥណ្ឌា ។

## គោលនៃការពិភាក្សា

១– អំពីពិធីបុណ្យសម្ពោធពុទ្ធសករាជគំរប់ ២៥០០ នឹងបំនួនរូបជនអធិយេសក៍ នៃប្រទេសនិមួយៗដែលមានបំណងទៅកាន់ប្រទេសឥណ្ឌា ។

២– ការបែងចែកទីដីដែលរដ្ឋាភិបាលពិហារជាវបានមក សម្រាប់សាងព្រះវិហារនឹងផ្ទះសំណាក់ ។

លោក ស.ក. មូគ័រជី ជាតំណាងរដ្ឋាភិបាលពិហារ បានថ្លែងប្រាប់ទីប្រជុំថា មុខការរបស់គណៈកម្មាធិការនេះ គឺគ្រាន់តែជជែកពិភាក្សាអំពីរឿងដែលត្រូវដាក់ឲ្យគណៈកម្មាធិការ អ្នកចាត់ចែងការប្រតិបត្តិតាម ។ រដ្ឋាភិបាលពិហារនឹងរៀបចំជាខលក្ខន្តិកសម្រាប់គណៈកម្មាធិការ ហើយនឹងដាក់ជូនសមាជិកទាំងអស់ពិនិត្យបញ្ចេញយោបល់ ។ មានខណៈនាំមួយកន្ទែងថា ប្រសិនបើអ្នកតំណាងនៃប្រទេសណាមួយមិនអាចទៅកាន់ទីប្រជុំបាន នោះអាចចាត់តាំង សមាជិកនៃបេសកកម្មទូតឬកុងស៊ុលជាតំណាងខ្លួនបាន ។

(នៅមានត)

# របនាវិលាសវាក្យភាសាអង់គ្លេស (ត)

2- Not being sure of the word, he TURNED IT UP in the dictionary.

3- While looking for an old letter. he TURNED UP a photograph of himself as a child.

4- She TURNS UP here half an hour late as usual.

### III- **To give up;**

( to surrender; to renounce.)

1- The enemy GAVE UP without any resistance.

2- King Edward GAVE UP his throne IN ORDER TO marry the woman he loved.

NOTE= in order to.

3- He has tried many time to GIVE UP smoking.

### IV- **To turno ver ;**

នោះចោល ។

ដោយការចាំមិនប្រាកដនូវពាក្យនោះ, គាត់បានបើករកមើលក្នុងវចនានុក្រម ។

ក្នុងពេលដែលកំពុងរកមើលសំបុត្រចាស់មួយ, គាត់បានប្រទះរូបថតមួយសន្លឹករបស់ខ្លួនគាត់កាលនៅក្មេង ។

អ្នកស្រីនោះ មកដល់ទីនេះ យឺតយូរកន្លះម៉ោងជាធម្មតា ។

ចេញចោល; លះបង់; ឈប់ (ធ្វើ)

ពួកសត្រូវបានរត់ចេញ ដោយឥតមានការតស៊ូអ្វីឡើយ ។

ព្រះរាជាព្រះនាម អិដ វ៉ដ បានលះបង់រាជបល្ល័ង្ក ដើម្បីរៀបការនឹងស្ត្រីដែលទ្រង់សព្វព្រះទ័យ ។

ដើម្បី; ដោយបំណង; ព្រោះប្រាថ្នា...។

គាត់បានព្យាយាមច្រើនលើក ដើម្បីឈប់ជក់បារី ។

ប្រែត្រឡប់ចុះឡើង; បញ្ចូនខ្លួន;

(to turn from side to side; to send on; to do business.)

1- Bacon, to be properly cooked, must be TURNED OVER once or twice (ថៃស៍)

2- The thief was TURNED OVER to the police.

3- He TURNED OVER one thousand piastres (កាស-ស្ត្រ) last week alone.

V- **To come to;**

(to revive)

1- She fainted and it was at least a half an hour before she CAME TO.

2- At first they thought that the man would be dead, but soon he CAME TO.

VI- **To turn out;**

(to evict; to become; to clean)

បំណាយធ្វើកិច្ចការ;

សាច់ជ្រូក (ប្រឡាក់) ដើម្បីឲ្យបានឆ្អិនល្អ ត្រូវតែប្រត្រឡប់ចុះឡើងម្តងឬពីរដង ។

ចោរនោះ ត្រូវគេបញ្ជូនខ្លួនទៅក្រុមនគរបាលហើយ ។

គាត់បំណាយចុះទុនក្នុងកិច្ចការតែម្នាក់ឯងអស់១ពាន់រៀល ពីអាទិត្យមុននេះ ។

បានស្រួលឡើងវិញ; បានធូរស្បើយ (នោះ) ។

នាងនោះត្រូវខ្យល់ចាប់ ហើយយ៉ាងតិចណាស់ កន្លះម៉ោងទើបបានស្រួលឡើងវិញ ។

ដំបូងគេគិតថា បុរសនោះមុខជានឹងស្លាប់, ប៉ុន្តែមួយរំពេចនោះ គាត់បានធូរស្បើយវិញ ។

បណ្តេញចេញ; ត្រឡប់ជា...; បោសជូតសំអាត;

(នៅមានត)

# ពាក្យថ្មីរបស់គណៈកម្មការវប្បធម៌ដែលប្រែចេញពីភាសាបារាំង

ពាក្យថ្មីដែលគណៈកម្មការវប្បធម៌បានប្រែចេញពីភាសាបារាំង ហើយកំណត់ទុកជាភាសាខ្មែរ នោះនឹងផ្សាយបន្តពីសៀវភៅមុនៗ ដែលក្រសួងសិក្សាធិការនឹងយុវជនបានផ្សាយរួចមកហើយ ។

A titre remboursable: ជាកិច្ចត្រូវសង ។

Accorder: ព្រមព្រៀង ។

Accroissement de production de l'énergie électrique du Camboge: ការបំពីននៃផលិតកម្ម ថាមពលអគ្គិសនី ។

Accusé de réception d'effets: លិខិតទទួលផលប័ត្រ ។

Achalandage: សម្បូណ៌បរិស័ទ ។

Acompte: ប្រាក់រំដោះ, ប្រាក់ដែលសងដោះបំណុល-បណ្ដើរ ។

Acquitter: ដោះដំពាក់ ។

Actif សកម្ម « ប្រាក់ឬវត្ថុដែលជារបស់ខ្លួន » ។

Action: កម្ម – អំពើ – ហ៊ុន ។

Actualités: រឿងបច្ចុប្បន្ន ។

Agence: ទីភ្នាក់ងារ – តំណាង ។

Agio: អតិប្រមាណ ។

Algèbre: ពីជគណិត ។

Allocation: វិភាជន៍ ។

| | |
|---|---|
| Amphitheâtre: | រង្គមណ្ឌល – រង្គដ្ឋាន |
| Amortissement: | ការរំលស់ – ការសម្រាល ។ |
| Appointements (mac. plur.) | និយុត្តិការ |
| Appointer: | ធ្វើនិយុត្តិការ |
| Apport: | ទុន – ភាគទុន – ឧបហារិត |
| Apport en espèce: | ភាគទុនជាប្រាក់ ។ |
| Apport en nature: | ភាគទុនជាធម្មជាតិ «វត្ថុក្រៅពីប្រាក់» ។ |
| Approuver: | យល់ព្រម |
| Arbitrage: | មជ្ឈត្តភាព – មជ្ឈត្តវិនិច្ឆ័យ ។ |
| Archéologie: | បុរាណវត្ថុវិទ្យា ។ |
| Archétypes | មូលរូប ។ |
| Arithmétique: | លេខគណិត ។ |
| Arrhes: | ប្រាក់កក់ |
| Article de fond | គម្ពីរបទ |
| Autel de la patiie: | អាសនៈ មាតុភូមិ ។ |
| Autoriser: | អនុញ្ញាតិ ។ |
| Bovidé: | គោសាទិស, ពួកសត្វសណ្ឋានជាគោ ។ |
| Bloc: | ដុំ - ដុល - ក្រុម - ពួក - វង់ |
| Billet à ordre | បណ្ណបញ្ជា «រឿងប្រាក់» ។ |

| | |
|---|---|
| Bilan: | តុល្យការ ។ |
| Beauté: | សោភនៈភាព លំអ ។ |
| Base décimale: | គោលដប់ ។ |
| Banquier: | ធនាគារិក |
| Balance des comptes: | តុល្យភាពគណនី ។ |
| Cabinet: | ខុទ្ទកាល័យ ។ |
| Caisse: | បេឡា "ប៊េឡា" ។ |
| Caisse générale: | បេឡាឧកាស ។ |
| Coissier génaral: | បេឡាធិការឧកាស ។ |
| Caissier particulier: | បេឡាធិការពិសេស ។ |
| Caissier principal: | បេឡាធិការបតី ។ |
| Catalogue | នាមវលិ |
| Cave: | លេណ - ភូមិគ្រិះ ។ |
| Caveau: | លេណកៈ ភូមិគ្រិះតូច ។ |
| Caverne: | គុហា |
| Censeur: | ពិរុទ្ធាបេក្ខ - អ្នកចាប់ពិរុទ្ធ ។ |
| Centre Equestre: | មជ្ឈមណ្ឌលអស្សារោហី "រោហ៊ី" |
| Centre Vétérinaire des Forces Armées Royales Khmères | មជ្ឈមណ្ឌលបសុពេទ្យ នៃសេន្យានុភាពខេមរភូមិន្ទ "ស. ខ. ភ." ។ |

( F. A. R. K. ):

| | |
|---|---|
| Cercle sportif otorium: | កីឡាមណ្ឌល សវនដ្ឋាន ។ |
| Charme: | ប្រមោហន ។ |
| Chambre de compensation: | អាគារទូទាត់ ។ |
| Chef de Cabinet: | នាយខុទ្ទកាល័យ ។ |
| Chenil militaire: | សុនខាគារទាហាន ។ |
| Chèque | មូលប្បទានប័ត្រ ។ |
| Chèque barré: | មូលប្បទានប័ត្រឆូត ។ |
| Chute d'eau | ទឹកធ្លាក់ - ជលប្បាត - ទឹកជ្រោះ |
| Clause | ខសំខាន់ ។ |
| Client: | អតិថិជន ។ |
| Clientèle | អតិថិកា ។ |

# បូរាណនិវេសន៍

មានទីកន្លែងចាស់មួយកន្លែងតាំងនៅទីដំបន់សង្គម ឃុំស៊ីធរស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ជាទីស្ថានបុរាណកាល ល្មមឲ្យគត់សំគាល់បានថាជាទីព្រះរាជធានី កន្លែងព្រះបរមរាជវាំង ក្រុងចាស់របស់ព្រះមហាក្សត្រជាន់ដើមស្ដេចគង់នៅមកអស់កាល ១៨០០ ឆ្នាំហើយ ព្រោះឃើញមានបុរាណវត្ថុនឹងស្នាមដំណែលវត្តអារាម ជាច្រើនកន្លែង ដែលគួរឲ្យទឹកស្ដាយ គួរឲ្យចង់ដឹងរបស់ទាំងនោះ ខ្ញុំសូមប្រវត្តិរឿងនេះទុក កុំឲ្យបាត់បង់កេរ្ដិ៍ដំណែលឈ្មោះរបស់លោកបុរាណជាន់ដើមតទៅ ។

កាលនៅថ្ងៃ២កើត ខែចេត្រ ព.ស.២៤៩៨ ត្រូវនឹងថ្ងៃ ១៣ ខែមិនា (Mars) គ. ស. ១៩៥៦ ។

សម្ដេចព្រះធម្មលិខិត ឧត្ដមប្រឹក្សា វត្តលង្កា ក្រុងភ្នំពេញ បានបំណាយបច្ច័យមួយម៉ឺនរៀល ឲ្យកសាងរបងវត្តស៊ីធរ ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ហើយបានទទួលនិមន្តគេទៅធ្វើបុណ្យឆ្លងរបងវត្តនោះ ដែលធ្វើអំពីសរសរបង្គោលស៊ីម៉ងត៍ ចងរបាំងលួសបន្លា ព័ទ្ធជុំវិញ ដើម្បីការពារសំអាតទីវត្តនោះទាំងមូល ។

ពួកអ្នកស្រុកចង់ដឹងអំពីរឿងរ៉ាវវត្តនោះណាស់ ព្រោះឃើញមានបុរាណវត្ថុ គឺព្រះពុទ្ធរូប ទេវរូប នឹងប្រាង្គចេតិយធំ ៗ ដែលដីដុះគ្របលិចចុះទៅក្នុងផែនដី ជាដើម តើវត្តនេះ គេបានកសាងជាយូរឆ្នាំហើយ ឬ ទើបនឹងកសាង? ការណ៍ចង់ដឹងនេះហើយ នាំឲ្យខ្ញុំចងក្រងការប្រវត្តិរបស់វត្តស៊ីធរនេះឡើង ដើម្បីយកទៅសូត្រ ប្រាប់ដំណឹងក្នុងពេលដែលឆ្លងបុណ្យរបងវត្តនោះ ។

ខ្ញុំដែលជាអ្នកចងក្រងការប្រវត្តិរបស់វត្តនោះ ដោយបានពិនិត្យស្ថានភាពទីងបុរាណវត្តដែលនៅមានក្នុងវត្តនោះខ្លះដោយបានដឹងឮអំពីសំណាក់ជនចាស់ទុំ អ្នកនៅក្នុងស្រុកភូមិនោះខ្លះ គេប្រាប់ថាទីកន្លែងនេះហើយដែលហៅថា: «បុរាណនិវេសន៍» គឺជាទីព្រះរាជធានីចាស់របស់ព្រះបរមក្សត្រជាន់បុរាណកាលគង់នៅ តាំងបានឃើញឯកសារមួយយ៉ាងសំខាន់ខាងព្រះពុទ្ធសាសនា នៅប្រទេសឥណ្ឌូចិនគឺជាសិលាចារឹកនៅវត្តស៊ុធរដែលលោកហ្សេ-ហ្សដែលអ្នកធ្វើយក្ខនៃវិជ្ជាស្ថាន ចាងហ្វាងសាលាបារាំងនៅចុងបូព៌ាប្រទេស លោកបានប្រែសេចក្ដីអធិប្បាយចេញពីសិលាចារឹកដែលគេបានប្រតិស្ឋានទុកនៅវត្តស៊ុធរសព្វថ្ងៃនេះ Un document capital sur le Buddhisme en indochine:

La stele de Vat sithor...

នៅផែនសិលាចារឹក ៤ ជ្រុងនោះ មានចារឹករឿងព្រះពុទ្ធសាសនា ចារឹកអក្សរជាភាសាសំស្រ្កឹត ពាក្យកាព្យឃ្លោង សេចក្ដីឧទ្ទិសដ៏ឧឡារិកចំពោះព្រះពុទ្ធ ព្រះធម្ម-ពោធិសត្វ, ព្រះបាទសម្ដេចជ័យវរ្ម័នទី៥... ជាដើមដែលគួរឲ្យសំគាល់បានថា ជាបុរាណនិវេសន៍ កន្លែងព្រះបរមរាជវាំងជាព្រះរាជធានីចាស់ ព្រោះស្ថានភាពរបស់វត្តសព្វថ្ងៃនេះគឺមានទីដីដែលគេលើកខ្ពស់ឡើង មានកំពស់ប្រហែលជា២ម៉ែត្រ គេបានកសាងវត្តទុកប្រហែលជាង៩០០ឆ្នាំបាយហើយ សម្រាប់ឲ្យព្រះសង្ឃគង់នៅ មានគោរម្យងារវត្តហៅជាវត្ត «ព្រះរាជនិវេសនដ្ឋាន» ស្រីសឈរ គួរយកជាតឹកតាងតាមមូលហេតុដើមបាន ថាជាបុរាណនិវេសន៍ប្រាកដថែមទៀត ។

ខ្ញុំដែលជាអ្នកចងក្រងរឿងនេះឡើង មិនបានដាក់ ព. ស. និង គ. ស. ដូចឯកសារ (Document) ទេ គឺនិយាយទៅតាមស្ថានភាពទីកន្លែងវត្ត ប្រាង្គចេតិយធំ ៗ

ស្រះបឹង ជាដើម ដែលជាស្នាដៃហត្ថកម្មរបស់បុរាណធ្វើមក ដើម្បីសើរើរបស់ទាំងនេះ ដែលរាក់កល់បាត់រូបរាងស្ទើរតែអស់ទៅហើយ ឲ្យអណ្ដែតឡើងវិញ គ្រាន់ទុកជាអនុស្សរណីយវត្ថុបំពោះពួកជនដែលកើតមកខាងក្រោយ ឲ្យស្គាល់មូលហេតុរបស់វត្ថុ "ព្រះរាជនិវេសនដ្ឋាន" ស្រីសឈរ ដែលហៅថាវត្តស៊ីធរសព្វថ្ងៃ ដូចមានសេចក្ដីពណ៌នាតទៅនេះ៖

វត្តព្រះរាជនិវេសនដ្ឋាន ស្រីសឈរ ជាវត្តបុរាណស្ថានចាស់ ដែលពួកពុទ្ធបរិស័ទ្ធ តាំងពីសម័យជាន់បុរាណ កាលបានកសាងមកប្រមាណជាង ៩០០ ឆ្នាំមកហើយ នៅទីកន្លែងវត្តនេះហើយ ដែលជាកន្លែងព្រះបរមរាជវាំងព្រះមហាក្សត្រសម័យដើម កន្លងទៅជាង ១៤០១ ឆ្នាំហើយ តាមដំណឹងក្នុងឯកសារ (Document) បារាំងសេសប្រាប់ថា៖ មានព្រះរាជា ១ ព្រះអង្គទ្រង់ព្រះនាម ជ័យវរ្ម័ន ទី ៥ ដែលជាស្ដេចពីកាលស័ករាជ ៨៩០ ៩៨៨ មានកិច្ចទាក់ទងទៅដល់ការធម្មសាស្ត្រក្នុងព្រះពុទ្ធសាសនា ទ្រង់បានរៀបចំកសាងជួសជុល ព្រះពុទ្ធរូបនឹងទេវរូបធ្វើអំពីថ្មជាថ្មីឡើង ហើយបានប្រតិស្ឋានដំកល់ទុកក្នុងទីវត្តព្រះរាជនិវេសនដ្ឋាននេះ សម្រាប់ជាពូជនីយដ្ឋានពុទ្ធសាសនប្បវេណីរបស់ជនខេមរជាតិ (ប្រហែលជាមានធ្វើបុណ្យដោះលែងពួកមនុស្សដែលមានទោសទុក្ខត្រូវគុកប្រវាក់អន្ទាក់ណែងណងឲ្យរួចពីទុក្ខភាព) នៅទីក្រុងនេះមានវត្តជាច្រើនកន្លែង គឺវត្តទួលសាលា វត្តទួលព្រះរាជទាយ៍ វត្តព្រះមហាអានន្ទ វត្តសាំងសាមី វត្តមហាញី វត្ត-ស្រះឈូក វត្តស្រះធន្ទ វត្តឯកទេសស្តាំ ឯកទេសឆ្វេង វត្តស្រះខ្ទិត (១) វត្តព្រះរាជនិ-វេសនដ្ឋាន តាំងនៅកណ្ដាលភូមិស៊ីធរសព្វថ្ងៃនេះ, បំណែកបឹងស្រះសុទ្ធតែដីកដោយ

១ វត្តទាំងអស់នេះ ខ្លះក៏មានសន្លឹកសីមានៅសល់សព្វថ្ងៃ ខ្លះគ្មាន ។

ហត្ថកម្មទាំងអស់ គឺវង់ផ្កាល បណ្តាយប្រហែល ១០០ ម៉ែត្រ ទទឹងប្រហែល ៦០ ម៉ែត្រ បឹងកប្បាស បឹងក្រពើ ស្រះព្រះរាជទាយ៍ ស្រះសាំងសាមី ស្រះធំនៅជិតបឹងទទង នៅក្បែរស្រះនោះមានផែនថ្មធំលិចចុះទៅក្នុងមាត់បឹងទទឹងទំនងជាទីកំពង់ផែ ដែលព្រះ-រាជាចុះស្រង់វារីជាទីសប្បាយព្រះទ័យ, ស្រះជ្រៃ ស្រះដូនតាន ស្រះឈ្លូក ស្រះឆន្ទ ស្រះ-ខិតនោះគឺជាទីដំណាក់ព្រះអង្គម្ចាស់ក្សត្រិយ៍គង់នៅទទួលព្រះពន្លានៅទីគោក បំណែកជិតមាត់បឹងទទឹង របស់ទាំងនេះរលាយរលប់ទ្រង់ទ្រាយ ស្ទើរតែមើលរូបរាងពុំស្គាល់ថាជាអ្វី បុរាណវត្ថុទាំងនេះសុទ្ធតែជាការរចនារបស់ព្រះរាជាជាន់បុរាណកាល គាត់តែងឡើងដើម្បីជាព្រះរាជនិវេសនក្នុងសង្គមដ្ឋាន ។ (នៅមានត)

---

## រឿងធនញ្ជយបណ្ឌិត

## ឧបត្តិកថា

ហេតុដែលនាំឲ្យកើតជារឿងនេះឡើង ដោយខ្ញុំបានមើលគម្ពីរលោកន័យ ទាំងបាលីនិងសេចក្តីប្រែដែលសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាវត្តលង្កា បានប្រែចេញពីបាលីជាតកមក នៅជាគម្ពីស៊ីករត ប៉ុន្តែសមតាមបាលីត្រឹមត្រូវណាស់ ហើយពិស្តារក្រៃជាច្បាប់បុរាណដ៏វិចិត្រ ទៅដោយផ្លូវធម៌និងផ្លូវលោក ហើយពីរោះគួរឲ្យចាប់ចិត្តដល់អ្នកអាននិងអ្នកស្តាប់ សុទ្ធតែមានបញ្ហាចោទឆ្លើយ មានអ្នកប្រាជ្ញមួយរូបសួរ អ្នកប្រាជ្ញ ៤ រូបចាំដោះស្រាយយ៉ាងច្បាស់លាស់ គឺអ្នកប្រាជ្ញបីនាក់ឆ្លើយតាមផ្លូវលោកីយ ពុំបានសមទៅតាមបញ្ហានោះ ៗ ឡើយ ។ មានអ្នកប្រាជ្ញមួយរូបឈ្មោះធនញ្ជយជាអង្គពោធិ-សត្វទ្រង់ដោះស្រាយសមទៅតាមរបៀបផ្លូវលោកនិងផ្លូវធម៌និងសមតាមបញ្ហានោះ ៗផង មានប្រយោជន៍ដ៏សំខាន់គ្រប់អន្លើទាំងអស់ គួរជាទីពេញចិត្តនៃវិញ្ញូជននានា ។ ខ្ញុំព្យា-

យាមមើលជាច្រើនចប់ ស្ទើរតែចាំគ្រប់បញ្ហា ហើយប្រាថ្នាចង់ឲ្យច្បាប់លោកន័យនេះផ្សាយទូទៅដល់កុលបុត្រក្នុងប្រទេស បានស្តាប់ងាយនឹងចាប់បែកប្រាជ្ញ, ទើបខ្ញុំព្យាយាមតែងរៀបរៀងជារបៀបសៀវភៅមួយ ៗ យកទៅជូនបណ្ណាគារសុមនសុវត្ថិ សុំឲ្យបោះពុម្ពផ្សាយក្នុងមមដវដ្ឋ បណ្ណាគារនោះមិនបានបោះពុម្ព ព្រោះច្រើនណាស់គ្មានសោហ៊ុយតាំងពីឆ្នាំ ១៩៤៩ ម្ល៉េះ ទើបខ្ញុំព្យាយាមតែងបំប្រួញឲ្យខ្លីចុះបន្តិចម្តង ៗ យកតែសេចក្តីទឹងប្រយោជន៍ដ៏សំខាន់ ៗ បានការ ហើយខ្ញុំបានយកអត្ថបទខ្លះទៅចុះទស្សនាវដ្តីសមាគមមិត្តពុទ្ធិកវិទ្យាល័យ ល្បងមើលដូចត្រង់សេចក្តីខាងគម្ពីរលោកន័យនឹងបរិវត្តកបញ្ហាប៉ុណ្ណោះ ទៅអស់លោកអ្នកដែលបានអានមើលឃើញពេញចិត្តជ្រះថ្លា ទើបក្រុមសមាគមនេះ សូមឲ្យខ្ញុំរៀបរៀងតទៅទៀត នឹងជានាបោះពុម្ពក្នុងទស្សនាវដ្តីមិត្តពុទ្ធិកវិទ្យាល័យផ្សាយតទៅដរាបដល់ចប់ ។ ទើបខ្ញុំមានកម្លាំងខំព្យាយាមរៀបរៀងធ្វើឡើងជាថ្មីទៀត ប៉ុន្តែមិនសូវមានលោកអ្នកប្រាជ្ញណាជួយផ្ទៀងផ្ទាត់ផងទេ ប្រឹងព្យាយាមតែម្នាក់ឯងស្មោះ អាងតែមានភិក្ខុសាមណេរជាកូនសិស្សអ្នកជួយសរសេរចម្លងមិនលែងនឹងខុសត្រូវខ្លះ អាងបណ្ណាធិការទស្សនាវដ្តីជាអ្នកចាំពិនិត្យផ្ទៀងផ្ទាត់ស្រាប់ផង ។ ប៉ុន្តែទោះបីយ៉ាងណាក៏មិនលែងមានភ្លាំងភ្លាត់ដែរ សូមលោកអ្នកអានទាំងឡាយ សង្កេតមើលយកសេចក្តីឲ្យហ្មត់ចត់ផងចុះ បើមានពាក្យពេចន៍ខុសឆ្គងត្រង់ណា មេត្តាអត់ទោសកុំសើចកុំយំអ្វី ព្រោះធ្វើការនេះប្រញាប់ណាស់ ។

រៀបនឹងឡើងកាន់ទស្សនាវដ្តីនេះ ខ្ញុំបានក្រាបបង្គំទូលសូមអនុញ្ញាតពីសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ដ្បិតគម្ពីរនេះជាស្នាព្រះហស្តរបស់សម្តេច ។ សម្តេចទ្រង់អនុញ្ញាតថា «ប្រពៃណាស់ហើយលោក ចូរបោះពុម្ពចុះផាន់ត្រេកអរណាស់» ទ្រង់ប្រទានពរជាច្រើន ។ល។

សូមឲ្យព្រះពុទ្ធសាសនាបានចំរើនរុងរឿងគ្រប់៥០០០ព្រះវស្សា សូមឲ្យព្រះមហាក្សត្រនិងព្រះមហាក្សត្រិយានី ព្រមទាំងសម្ដេចព្រះឧបយុវរាជនរោត្ដម សីហនុ និងព្រះរាជវង្សានុវង្ស បានប្រកបទៅដោយសុខភាពវឌ្ឍនភាពក្នុងសិរីរាជសម្បត្តិអស់កាលជាអង្វែងតទៅ ព្រមទាំងព្រះរាជរដ្ឋាភិបាល និងពុទ្ធបរិស័ទក្នុងកម្ពុជរដ្ឋ ក៏សូមឲ្យបានសម្រេចដោយពរ ៥ ប្រការគឺៈ អាយុៈ, វណ្ណៈ, សុខៈ, ពលៈ, បដិភាណៈ សព្វ ៗ កាលកុំបីឃ្លៀងឃ្លាតឡើយ ។

រៀបរៀងនៅមន្ទីរគ្រូវិកុដិ វត្តលង្កា ក្រុងភ្នំពេញ

ថ្ងៃអាទិត្យ ១០ កើត ខែអាសាឍ ឆ្នាំវកអដ្ឋស័ក ត្រូវនឹងថ្ងៃទី១៧ខែមិថុនា

ព.ស. ២៤៩៩ គ.ស. ១៩៥៦

ព្រះគ្រូបុត្តមវាលី អ៊ូ-ចេវ

# ធនញ្ជយបណ្ឌិត

កាលដែលកើតគម្ពីរលោកន័យឡើងក្នុងពុទ្ធកាល ដូចមានសេចក្ដីតទៅនេះ ៖

ដំណើរដើមដំណាលថាៈ ក្រោយពេលដែលព្រះអរហំសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់ប្រោសអង្គុលិមាល៍ បានជាព្រះអរហន្តសាវកដ៏វិសេសនោះ ពួកពុទ្ធបរិស័ទទាំងឡាយប្រជុំគ្នាសរសើរបញ្ញាបារមីព្រះអង្គជាច្រើនក្រៃពេក ព្រះសង្ឃទាំងឡាយមានព្រះអានន្ទជាដើម បានឮហេតុដូច្នោះហើយក៏នាំសេចក្ដីនោះចូលក្រាបបង្គំទូលសួរចំពោះព្រះដ៏មានបុណ្យ; ព្រះលោកុត្តមាចារ្យ ទ្រង់លើកព្រះហស្ថចង្អុលអង្គុលិមាលតេរថាៈ ម្នាលអានន្ទ ឥឡូវនេះតថាគតបានត្រាស់ជាព្រះពុទ្ធហើយមិនជាអស្ចារ្យប៉ុន្មានទេ បើកាល

មិនទាន់ត្រាស់ដឹងនៅឡើយ ហើយអាចទូន្មានយក្សកំណាចឲ្យមានចិត្តស្លូតបូតប្រព្រឹត្តសុចរិតឡើងវិញបាន នោះទើបគួរស្ញើចអស្ចារ្យមែនអានន្ទ ; ត្រាស់តែប៉ុណ្ណោះព្រះអង្គក៏ទ្រង់គង់នៅស្ងៀម ។ ព្រះអានន្ទត្ថេរទូលសូមអារាធនាថា ភន្តេ ភគវា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសនាំនិទានបុព្វេនិវាសជាតិដែលប្រសើរអស្ចារ្យជាងឥឡូវនេះ តើដូចម្តេចខ្លះព្រះអង្គ ?

ទើបព្រះអង្គទ្រង់ប្រទានធម៌ទេសនាថា : ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ អ្នកពល់គ្នាប្រុងចាំស្តាប់ដោយគោរពចុះ តថាគតនឹងនាំអតីតនិទានជាទីសណ្តាប់ដល់អ្នកពល់គ្នាដូចតទៅនេះ ។

អង្គុលិមាលភិក្ខុនេះ កាលពីដើមកើតជាយក្សឈ្មោះថា នន្ទិយក្ស អាស្រ័យនៅនាដើមជ្រៃមួយ ដើមធំក្នុងព្រៃស្ងាត់ ដោយបានអំណាចអំពីស្តេចវេស្សវណ្ណប្រគល់ឲ្យចាប់នរណាក៏ដោយឲ្យតែចូលមកជ្រកក្រោមម្លប់ជ្រៃនេះ បរិភោគជាចំណីបានទាំងអស់ វៀរលែងតែនរណាបេះមលគរធម៌មិនត្រូវចាប់ឡើយ ។

ម៉្លោះហើយយក្សតែងចាប់មនុស្សសម្លាប់ស៊ីពល់ៗថ្ងៃមិនដឹងអស់ប៉ុន្មាននាក់ទេ រាប់មិនអស់ ។

ម្នាលភិក្ខុទាំងឡាយ កាលណោះមានស្តេចមួយព្រះអង្គទ្រង់ព្រះនាម ធនញ្ជយកោរព្យរាជ ជាព្រះចៅក្នុងនគរឥន្ទបត្តបុរី ព្រះអគ្គមហេសីទ្រង់ព្រះនាមអតុលាទេវីជាចម្បងលើស្ត្រីមួយម៉ឺនប្រាំមួយពាន់នាក់ដែលជាបរិវារ; ព្រះរាជាអង្គនេះ ចំរើនរុងរឿងណាស់ ប្រកបដោយពួកពលសកលយោធាចតុរង្គសេនា១ អក្ខោភិនី មានស្រុកធំ៤គឺ បាចីនគ្រាម១, ទក្ខិណគ្រាម១, បច្ឆិមគ្រាម១, ឧត្តរគ្រាម១ តែងនាំសួយសារ

អាករឡើងថ្វាយជាទិច្ច, មានសេដ្ឋីធំ៤នាក់គឺ ធនញ្ជយសេដ្ឋី នៅទៀបទ្វារខាងកើត១, វិសាលសេដ្ឋីនៅទៀបទ្វារខាងត្បូង១, សុចិសេដ្ឋី នៅទ្វារខាងលិច១, ទុស្សនសេដ្ឋី នៅទៀបទ្វារខាងកើត១ ។ សេដ្ឋីធំទាំង៤នាក់នេះ ម្នាក់ៗមានអនុសេដ្ឋី ៥០០ ៗ ជាបរិវារដូចគ្នា ។

កាលណោះ ព្រះពោធិសត្វជាទេវបុត្រ ច្យុតចាកទេវលោកមកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងសុខមាលីជាភរិយានៃធនញ្ជយសេដ្ឋី មានទេវបុត្រ ៥០០ ចុះមកចាប់បដិសន្ធិក្នុងផ្ទៃភរិយានៃអនុសេដ្ឋី ទាំង ៥០០ ចុះមកចាប់ជាបរិវារនៃធនញ្ជយសេដ្ឋីនោះក្នុងវេលាជាមួយគ្នាផង ។

ព្រះបាទធនញ្ជយកោរព្យរាជ ទ្រង់សុបិននិមិត្តឃើញថា គំនរភ្លើងធំបួនដើមគោគនេះឡើងតម្រង់មុខទីព្រះលានជ័យ មានផ្កាកម្ពុធំប៉ុនកង់រាជរថ ផុះឡើងចំកណ្ដាលគំនរភ្លើងធំអណ្ដាតភ្លើងក៏រលត់បាត់ទៅ, ផ្កាកម្ពុនោះមានពន្លឺក្លិនក្រអូបក្រាលឡើងផ្សាយទៅក្នុងជម្ពូទ្វីបទាំងមូលជាអស្ចារ្យ ព្រះរាជាត្រាស់ឲ្យហៅបុរោហិតមកទាយក្ដាម ។ ព្រាហ្មណ៍បុរោហិតទាយថា:

ទេវ បពិត្រព្រះសម្មតិទេព ឯគំនរភ្លើងធំនោះគឺ: ខ្ញុំទូលព្រះបង្គំ ជាអ្នកប្រាជ្ញចាស់សម្រាប់ព្រះអង្គ ចំណែកផ្កាកម្ពុនោះគឺ: មានអ្នកប្រាជ្ញកើតឡើងថ្មីទៀតហើយ, ឯពន្លឺដែលក្លិនអស្ចារ្យផ្សាយទៅពេញជម្ពូទ្វីបនោះគឺ: អ្នកប្រាជ្ញនោះមានប្រាជ្ញាដ៏មុះមុតជាងអ្នកប្រាជ្ញឯទៀតៗទាំងអស់ អាចជួយដោះទុក្ខភយន្តរាយចំពោះព្រះអង្គឲ្យរួចផុតទាំងអស់បាន បពិត្រមហារាជអ្នកប្រាជ្ញនោះ បានចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាគាំរប់ ១០ខែហើយ នឹងប្រសូត្រចាកគភ៌ក្នុងថ្ងៃនេះឯង ។ គ្រានោះនាងសុខមាលីប្រសូត្រ

បុត្រព្រមទាំងកិរិយានៃអនុសេដ្ឋី ៥០០ ក៏ប្រសូត្រដំណាលគ្នាដែរ, ស្រាប់តែស្គរទន្ទេរគេរ ដ៏យលាន់ឮរំពងឡើងឯង សាយភាយរន្ទឺឮទៅក្នុងឧត្តរកុរុទ្វីបទាំងមូលជាចម្លែកផ្លែក អស្ចារ្យ ៗ ព្រះញាតិវង្សថ្វាយនាមពោធិសត្វថាធនញ្ជយកុមារ ៗ ព្រះរាជាបានទ្រង់ព្រះ សណ្ដាប់នូវសូរសំឡេងស្គរលាន់ឡើងខ្ទរឯងដូច្នោះ ទ្រង់ព្រួយព្រះរាជហឫទ័យក្រៃពេក មិនដឹងជាមានហេតុគេចយ៉ាងណា ត្រាស់បង្គាប់ឲ្យអញ្ជើញហោរាមកប្រឹក្សាភ្លាម ព្រាហ្មណ៍បុរោហិតក្រាបទូលថា: សូមព្រះអង្គកុំព្រួយព្រះរាជហឫទ័យអ្វី អ្នកប្រាជ្ញកើតឡើង ក្នុងថ្ងៃនេះហើយ បានជាទន្ទេរគេរដ៏យលាន់ឮឯង ដូច្នេះសូមទ្រង់ជ្រាប ៗ

ព្រះរាជាទ្រង់ព្រះសណ្ដាប់បុរោហិតទំនាយដូច្នោះហើយទ្រង់ចាត់អាមាត្យ ៤ នាក់ឲ្យ ចេញទៅកាន់ទិសទាំង ៤ ដើម្បីស៊ើបសួររកកូនទារណា កើតក្នុងថ្ងៃនេះ? អាមាត្យដែល ចេញទៅតាមទ្វារខាងកើតបានដឹងថា នាងសុមាលីជាភរិយាធនញ្ជយសេដ្ឋីព្រមទាំង ភរិយាអនុសេដ្ឋីទាំង ៥០០ ទើបតែសម្រាលបុត្រហើយថ្មីៗ ដំណាលគ្នាក្នុងថ្ងៃនេះដូច្នោះ ក៏នាំសារមកក្រាបទូលស្ដេចតាមដំណើរ ៗ ព្រះរាជាទ្រង់ជ្រាបដំណឹងច្បាស់លាស់ ហើយ មានព្រះរាជហឫទ័យសោមនស្សរីករាយជាពន្ទឹក ទ្រង់ព្រះរាជទានប្រាក់១ពាន់ កហាបណៈ នឹងមេនំ ៤ នាក់ព្រមទាំងគ្រឿងប្រដាប់សម្រាប់កុមារដល់ធញ្ជយសេដ្ឋី ប្រទាន ៥០០ៗ កហាបណៈដល់មេនំម្នាក់ៗទៀត សម្រាប់ចិញ្ចឹមកុមារទាំងអម្បាល នោះ ៗ ទ្រង់តាំងព្រះទ័យទុកថា: ដល់កុមារទាំងនេះធំឡើងកាលណានឹងបានសាកសួរ ល្បងប្រាជ្ញាមើល ៗ អបរភាគេ លុះបំណេរមកខាងក្រោយ ធនញ្ជយកុមារចំរើន វ័យធំឡើងហើយ ប្រកបដោយរូបឆោមលោមព័ណ៌ល្អអស្ចារ្យ ឯកុមារទាំង ៥០០នាក់ ក៏ចំរើនវ័យវឌ្ឍនាការស្មើគ្នាដែរ តែងដើរតាមចោមរោមព្រះបរមពោធិសត្វហូរហែមក ៗ

នៅមាន (ត)

# ក្រុងរង្គូន ប្រទេសភូមា

## ពិធីបុណ្យឆ្លងឆដ្ឋសង្គាយនានិងបុណ្យពុទ្ធជយន្តិ

ឆដ្ឋសង្គាយនាដែលប្រទេសភូមាបានខំប្រឹងប្រែងធ្វើដោយមហុស្សាហ៍តាំងពីបឋមសន្និបាតរហូតមកដល់បញ្ចមសន្និបាតនេះ អស់រយៈវេលាប្រមាណពីរឆ្នាំ ។ ក្នុងរង្វង់កាលនៃឆដ្ឋសង្គាយនានោះ ប្រទេសភូមាបានចំណាយប្រាក់ដើម្បីការចាំបាច់យ៉ាងច្រើនទាល់តែថវិកាជាតិធ្លាក់ចុះក្នុងស្ថានការណ៍ដ៏លំបាក ដូចយ៉ាងកសាងព្រះមហាបាសាណគុហា១, មហាកុដិទាំង៤, មន្ទីរពេទ្យ១, រោងពុម្ព១, រោងភត្ត១, និងមន្ទីរចាត់ការ១ ។

មហាបាសាណគុហាអស់តម្លៃ ៩១ សែនក្យាត់(១), ទំហំខាងក្រៅបណ្ដោយ ៤៥៥ ហ៊ូត(២), ទទឹង ៣៧០ ហ៊ូត; ទំហំខាងក្នុង បណ្ដោយ ២២០ ហ៊ូត, ទទឹង ១៤០ ហ៊ូត មានកន្លែងអង្គុយបំណុះមនុស្ស ១០.០០០ នាក់ ។

មហាកុដិទាំង ៤ ដាក់ភិក្ខុបានចំនួន ១.០០០ អង្គកសាងអស់តម្លៃ ៣.៣០០០.០០០ ក្យាត់ ។

ភត្តសាលាមួយល្មមភិក្ខុ ១.៥០០ អង្គគង់ឆាន់បានក្នុងមួយពេល រួមទាំងកន្លែងចំអិនដែលប្រើសុទ្ធម៉ាស៊ីនចំអិន អស់តម្លៃ ១២០០.០០០ ក្យាត់ ។

មន្ទីរពេទ្យសម្រាប់ចែកថ្នាំនិងព្យាបាលភិក្ខុទាំងឡាយនៅពេលឆដ្ឋសង្គាយនា, មានគ្រែសឹង ៤០, អស់តម្លៃ ៥០០.០០០ ក្យាត់ ។

កន្លែងចាត់ការមួយយ៉ាងធំអស់តម្លៃ ៥០០.០០០ ក្យាត់ ។

---

(១) ប្រាក់ភូមាតម្លៃស្មើប្រាក់ខ្មែរ ៧៖៥០

(២) រង្វាស់អង់គ្លេស ប្រវែងពីចុងជើងដល់កែងជើងមនុស្សចាស់

កោះពុម្ពមួយសម្រាប់បោះពុម្ពព្រះត្រៃបិដក បាលី-ភូមាអស់តម្លៃ ៣០០.០០០ ក្យាត់ ។

ព្រះមហាបាសាណគុហានឹងគ្រឹស្ថានទាំងអស់ធ្វើហើយស្រេច ក្នុងវេលា ១៨ខែ សល់តែមន្ទីរចាត់ការមួយប៉ុណ្ណោះ តែហើយស្រេចនៅពេលក្រោយបន្ទាប់ពីនោះមកបន្តិច

ក្នុងសម័យនៃឆដ្ឋសង្គាយនានោះ រដ្ឋាភិបាលប្រទេសភូមា បានអញ្ជើញប្រទេសជាពុទ្ធសាសនិកទាំងអស់ទាំងហីនយាន (ថេរវាទ) នឹងមហាយាន (អាចរិយវាទ) ទៅរួមប្រជុំធ្វើសង្គាយនា ។ ប្រទេសពុទ្ធសាសនិកទាំងនោះក៏បានបញ្ជូនប្រតិភូរបស់ខ្លួនទៅកាន់ទីប្រជុំនោះពល់តែសន្និបាត ប្រទេសខ្មែរយើងក៏បានទៅរួមប្រជុំពល់លើកដែរ ដូចតាលពីះ

១– បឋមសន្និបាត ព្រះរាជរដ្ឋាភិបាលប្រទេសយើងបាននិមន្តសម្តេចព្រះមហាសុមេធាធិបតី (ជ-ណ) សង្ឃនាយកគណៈមហានិកាយទៅជាប្រធាននៃគណៈប្រតិភូព្រះសង្ឃខ្មែរ ។

២– ទុតិយសន្និបាត ព្រះរាជរដ្ឋាភិបាលបានចាត់ព្រះតេជព្រះគុណព្រះពោធិវង្ស ឲ្យនិមន្តទៅជាប្រធាននៃប្រតិភូខ្មែរ, នៅពេលនោះឯង សម្តេចព្រះឧបយុវរាជ កាលដែលទ្រង់គង់នៅក្នុងរាជសម្បត្តិនៅឡើយ បានស្តេចយាងទៅបើកសម័យប្រជុំលើកទីពីរនោះទៀតផង ។

៣– នៅពេលតតិយសន្និបាតទៀត រដ្ឋាភិបាលប្រទេសភូមាបានសុំនិមន្តសម្តេចព្រះមហាសុមេធាធិបតីទៅជាប្រធាននៃតតិយសន្និបាតឆដ្ឋសង្គាយនា ដោយអាកាសយានពិសេស ដែលប្រទេសភូមាបានចាត់ឲ្យមកនិមន្តសម្តេចទៅ ។ (នៅមានត)

# ជ័យប្រាជ្ញ (ត)

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយមានព្រះបន្ទូលថាបពិត្រលោកម្ចាស់! ពាក្យអាជ័យវាថានេះ ឃើញថា វាសរសើរលោកម្ចាស់មែន ៗ សូមលោកម្ចាស់កុំប្រកាន់ទោស ៗ តាបសក៏ទទួលព្រមសុខចិត្តដោយតុណ្ហីភាព ៗ

X X X

កុមារជ័យក្រាបថ្វាយបង្គំលាព្រះមហាក្សត្រ ៗ ទ្រង់មានព្រះបន្ទូលថា នែ! អាជ័យ! អាឯងទៅផ្ទះចុះ កុំចូលមកកាន់វាំងអញទៀត ៗ

ពួកអស់អ្នកឮព្រះមហាក្សត្រទ្រង់បណ្ដេញកុមារជ័យដូច្នោះ ក៏មានសេចក្ដីត្រេកអរជាទីបំផុត ៗ ចំណែកកុមារជ័យកាលណាដើរចេញមកហើយ ក៏ញាក់មុខញាក់មាត់បណ្ដើរពួកអស់អ្នកឃើញដូច្នោះ ក៏ស្រដីទៅកាន់កុមារជ័យថានែ! អាជ័យ! កាប់កទៅឲ្យស្រឡះស្រឡៀនទៅ អញស្អប់មុខអាឯងណាស់ ៗ

កុមារជ័យ - ឱ! ប្រាកដជាអ្នកបងស្អប់មុខខ្ញុំមែនឬ? ៗ

ពួកអស់អ្នក - ហៃ! កុំចាប់អាឯងង៉ាកមុខត្រឡប់មកនិយាយនឹងអញធ្វើអី មុខអាឯងនេះអញស្អប់ណាស់អញមិនចង់ឃើញបន្តិចបន្តួចសោះ ចូរអាឯងចេញឲ្យឆាប់ទៅ ៗ

កុមារជ័យ - អ្នកបងប្រាកដជាស្អប់មុខខ្ញុំមែនឬ ថាលេងទេ ៗ

ពួកអស់អ្នក - បើអញមិនស្អប់ ចាំបាច់អញនិយាយឲ្យអាឯងដឹងខ្លួនធ្វើអី ៗ

កុមារជ័យ - សាធុ! បើប្រាកដជាស្អប់មុខខ្ញុំមែន មុខជានឹងមានការធ្វើហើយ ៗ

ពួកអស់អ្នក - នែ! អាជ័យ! អាឯងមានការធ្វើយ៉ាងម៉េច? ៗ

កុមារជ័យ - ទាទេ! មានការធ្វើខ្លួនខ្ញុំ ព្រោះតែអ្នកបងស្អប់មុខនេះ ៗ

ពួកអស់អ្នក - ណ្ហើយ! ចេញឲ្យឆាប់ទៅអញមិនចេះស្ដាប់ពាក្យអាឯងទេ ៗ

កុមារជ័យក៏សំរេចដៃ ឱនក្បាលគោរពពួកអស់អ្នកទាំងនោះហើយ ដើរចេញមកក្រៅព្រះបរមរាជវាំង ។

ពួកអាមាត្យដែលនៅខាងក្រៅវាំងប៉ុន្មាន លុះឃើញកុមារជ័យដើរចេញមកវិញហើយ នាំគ្នាបួញមាត់បួញកបញ្ចេញអាការស្អប់ខ្ពើមកុមារជ័យ ៗ ក៏ឃើញអាការៈដែលពួកអាមាត្យធ្វើបែបដូច្នោះ ដើរមកបណ្តើរធ្វើជាក្អកបណ្តើរ ខាកស្តោះធ្វើទៅខាងណេះម្តងទៅខាងណោះម្តង ។

ពួកអាមាត្យឃើញកុមារជ័យបញ្ចេញអាការធ្វើកដូច្នោះក៏សួរថា នែ! អាជ័យ! ហេតុអ្វីក៏អាឯងក្អកបង្អើ ខាកស្តោះធ្វើយទៅខាងណេះម្តងខាងណោះម្តងដូច្នោះ ។

កុមារជ័យ-ជំរាបប្រសាសន៍លោក! បានជានាំឲ្យខ្ញុំក្អកបង្អើរយ៉ាងនេះ មកពីខ្ញុំនឹកទៅខ្ពើមខ្លួនឯង ដោយហេតុថាខ្លួនគគ្រិចគួរឲ្យគេខ្ពើមល្អើមយ៉ាងនេះ មិនគួរព្រះករុណាជាអម្ចាស់ជីវិតលើត្បូងហៅឲ្យចូលព្រះបរមរាជវាំងសោះ ដូចជាពាក្យអស់លោកបានទាយទុកពីថ្ងៃមុនថា ដល់សេះដុះស្នែងទើបខ្ញុំចូលវាំងបាន ឥឡូវនេះមិនដូច្នោះ ប្រែត្រឡប់ជាព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ត្រាស់ហៅឲ្យចូលមកដូចពាក្យខ្ញុំជំរាបអស់លោក ឃើញថាជាការផ្ទុយនឹងទំនាយរបស់អស់លោកពីថ្ងៃមុននោះស្រឡះ ហេតុនេះបានជានាំឲ្យខ្ញុំខ្ពើមល្អើមខ្លួនឯងព្រោះនឹកទៅឃើញតែការគគ្រិចនោះ មិនអស់មិនហើយសោះ ។

បំណែកខាងអស់លោកសុទ្ធតែគ្រាន់បើជាងព្រះមហាក្សត្រទៅទៀត បានជាយល់ហួសហើយធ្វើទំនាយដូច្នេះ ។

នៅមាន (ត)

រោងពុម្ពទរិយ
នៅខាងត្បូងផ្សារអូរឬស្សីសង្កាត់លេខ៥